ឆ្នាំទី ៤ ... លេខ ១០
ថ្ងៃទី ១ ... ខែតុលា

Cs.3.4 2(47)

ទស្សនាវដ្តី

# មិត្តសាលាបាលី

ផ្សាយចេញ

សាសនា, អក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ

ព.ស. ២៤៩៧ ចេញរាល់ថ្ងៃទី ១ ខែ

គ.ស. ១៩៥៤ ប្រក្រតិទិនសុរិយគតិ



ប្រាសាទបុរះណាគោយ៉ា (ប្រទេសជប៉ុន)

បណ្ណាធិការ ហួត-ហៀម

ក 47 2

រោងពុម្ព គាភ លេខ ០៩៩ វិថីព្រៃនគរ ភ្នំពេញ

ថ្វាយព្រះពរក្នុងឱកាសបុណ្យបម្រើនព្រះជន្មវស្សា ឆ្នាំ ១៩៥៤
បំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង

សមាគម មិត្តសាលា បាលីសូម ព្រះករុ- ណាទ្រង់ជ្រាប រាជវង្សា
គុណត្រ័យរតន៍ ពុទ្ធធម៌សង្ឃ ពរបេស្តា គង់ជាសុខ ក្នុងរដ្ឋា រាជសម្បត្តិ ។
បុណ្យកុសល សមាគម ធ្វើប៉ុន្មាន សូមថ្វាយផល់ មហាក្សត្រក្សាន្ត ចាកវិបត្តិ
ផុតពីទុក្ខ សោករោគភ័យ បុណ្យកំចាត់ សប្បាយស្រួល ក្រោមស្វេតច្ឆត្រ អស់យូរលង់ ។

## មាតិការឿង


| | | | |
|---|---|---|---|
| | | ................វិចារណកថា | ទំព័រ ១ |
| មហាឧត្តមវិជ្ជា | ស្វយ-សុជ៌រ | ................បេះដូងខ្មែរសម័យ | " ២ |
| លោក | ស្ងួន-សារិទ្ធ | ................នរកនៅឯណា ? | " ៣ |
| លោក | ញ៊ូ-ប៊ូ | ................រឿងគួរឆ្ងល់ | " ៦ |
| លោក | ដេង-ជ្រីវ | ................បញ្ហា:ពោលអំពីមនុស្សស្បែកខ្មៅ | " ៨ |
| ព្រះសមុហ៍ | សៅ-ចេស | ................ជំបូន្មានកាព្យពាក្យ ៧ | " ១០ |
| | | .........,..... សន្និសីទ (តចប់) | " ១២ |
| ព្រះមហា | ធួត-ធឹម | ................អសោកមហារាជ | " ១៤ |
| ព្រះពុទ្ធវង្ស | គៅ-ស៊ុម | ................ពិធីបុណ្យបញ្ចុះអដ្ឋធាតុនិងសីមា (តចប់) | " ១៦ |
| លោក | រ៉ាយ-ប៊ុគា | ................ដំណើរទៅស្ទឹងទន្សាយ (ត) | " ១៩ |
| លោក | រ៉ាយ-ប៊ុគា | ................រឿងតុក្កតាធ្វើពីទធិជាតិ | " ២១ |
| លោក | តែ-ផុន | ................រឿងជ័យប្រាជ្ញ (ត) | " ២៤ |
| | | ................ប្រវត្តិក្មេងកំព្រា (ត) | " ២៦ |
| | | ..............ប្រវត្តិខេត្តបាត់ដំបង | " ៣០ |



អ្នកទទួលឲ្យជាវ

សូមផ្ញើចំពោះទៅលោកម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ ។

**adresse:** *Monsieur* **Mao-Mey** *Ministère de l'intérieur P. Penh*



# ព្រះពុទ្ធសាសនាជាសាសនាប្រចាំរដ្ឋ

## រដ្ឋធម្មនុញ្ញមាត្រា ៨

ប្រទេសសេរីទាំងឡាយតែងមានសាសនាប្រ-ចាំរដ្ឋ សាសនានេះគេត្រូវចែងទុកក្នុងមាត្រានៃរដ្ឋធម្មនុញ្ញ ដែលទីប្រឹក្សាបានយល់ឃើញថាជាសាសនាមានផលប្រយោជន៍ដល់ប្រជាជនអ្នកកាន់ ។

ចំណែកប្រទេសកម្ពុជាយើងគេបានលើកព្រះពុទ្ធសាសនាជាសាសនាប្រចាំរដ្ឋ ; ពាក្យថាសាសនាប្រចាំរដ្ឋនេះ បានសេចក្ដីទូលំទូលាយណាស់គឺថា ជនណាមួយមិនអាចលុបបំបាត់សាសនានេះបានទេ ហើយថែមទាំងត្រូវយកចិត្តទុកដាក់ជាបំផុតចំពោះការអនុវត្តន៍ឲ្យបានទូទៅក្នុងរដ្ឋនិងក្រៅរដ្ឋ ។ ហេតុដូចនោះហើយ បានជានៅក្នុងរដ្ឋទាំងឡាយដែលមានព្រះពុទ្ធសាសនាជាសាសនាប្រចាំរដ្ឋនោះ គេបានទំផ្សាយឥទ្ធិពលនៃព្រះពុទ្ធសាសនាយ៉ាងក្រៃលែង ដូចជានៅប្រទេសភូមា រដ្ឋាភិបាលសាធារណរដ្ឋភូមា ដែលមាន ឯ.ឧ.អ៊ូ.នុជានាយករដ្ឋមន្ត្រី; ឯ.ឧ.ព្រមទាំងសហការីបានពួតដៃគ្នាយ៉ាងពេញទំហឹងជាមួយនឹងពុទ្ធបរិសទ្យនៃសាធារណរដ្ឋភូមា ធ្វើឲ្យប្រជាជាតិក្នុងប្រទេសនោះកប់កានជឿកាន់ស៊ើរតែគ្រប់គ្នា សព្វថ្ងៃនេះគេឃើញចំនួនអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងសុទ្ធសាធមានកើនដល់ទៅកៅសិបភាគរយ (៩០ %)

រដ្ឋមន្ត្រីសាធារណរដ្ឋប្រទេសភូមាបានយកវិជ្ជាផ្នែកព្រះពុទ្ធសាសនាដាក់ឲ្យមានក្នុងកម្មវិធីបង្រៀនគ្រប់សាលាជាសាធារណៈក្នុងប្រទេស ទោះបីសាលានោះជាសាលានៃជនបរទេសក៏ដោយ ត្រូវតែឲ្យមានបង្រៀនច្បាប់ព្រះពុទ្ធសាសនាដោយដាច់ខាត ។

ចំណែកប្រទេសកម្ពុជាយើង សព្វថ្ងៃរាជរដ្ឋាភិបាលកំពុងតែប្រឹងប្រែងខ្លាំងណាស់ដែរ ចំពោះរឿងនេះមានទាំងបានស្ថាបនាឡើងនូវមហាវិទ្យាល័យព្រះពុទ្ធសាសនាមួយកន្លែង ដែលកំពុងតែសង់នៅខាងជើងសាលាបាលីជាន់ខ្ពស់សព្វថ្ងៃ នេះជាទម្រង់រូបមួយយ៉ាងវិសេសដែលព្រះពុទ្ធសាសនាប្រទេសកម្ពុជាពុំធ្លាប់គតប្រសប់ជាយូរមកហើយ ។

តែបើពោលទៅតាមគោលដើមនៃសេចក្ដីចំរើនវិញ ក៏គួរតែបង្កើតកម្មវិធីមួយផ្សេងទៀត ដែលជាកិច្ចឲ្យមានការសិក្សាព្រះពុទ្ធសាសនា ដោយបញ្ចូលពេលទៅក្នុងសិក្សាគារទាំងឡាយនៃកម្ពុជរដ្ឋឲ្យសិស្សទាំងនោះ ស្គាល់អត្ថរសនិងដម្លៃនៃព្រះពុទ្ធសាសនា ដើម្បីជាការភ្ញាក់រលឹកនៃពលរដ្ឋក្នុងប្រទេសដោយរួសរាន់ ។

សេចក្ដីនេះ យើងខ្ញុំសូមអំពាវនាវដោយគោរពចំ-

ព្រោះរាជរដ្ឋាភិបាលដែលមានឯកឧត្តម ប៉ែន-នុត ជានាយករដ្ឋមន្ត្រីមេត្តាជួយសម្រេចទៅតាមយោបល់ដ៏ថ្លៃថ្លារបស់ឯកឧត្តម ទើបមានសង្ឃឹមថាអាចអនុវត្តន៍ទៅបាន តាមគោលការណ៍ណាមួយដោយពិត ៗ

រស្មីព្រះពុទ្ធសាសនា

---

# បេះដូងខ្មែរសម័យ

ខ្មែរកម្ពុជាជាន់ឥឡូវ កាត់ទៅខ្មោចនុខ្មែរអង្គរ ខ្មែរទាំងស្រីប្រុសឡើងក្រោកឈរ ប្រឹងទប់ជំហរយ៉ាងអង់អាច ៗ ខ្មែរទាំងចាស់ក្មេងប្ដូរជីវិត ទើបខ្មែរអត់ឥតកោតខ្លាច ខ្មែរខំសាងខ្លួនជាអ្នកប្រាជ្ញកសាងអំណាចកម្ពុជា ៗ ខ្មែរនឹកខ្មាសណាស់ជាតិដទៃ ព្រោះខ្មែរធ្លាប់ល្បីពេញលោកា ខ្មែររួមគ្នាច្រោងកម្ពុជា ឲ្យបានជាមហាអំណាចវិញ ៗ ខ្មែរស្ដាយផែនដីកម្ពុជា ធំក្រៃមហិមាឥតទុកខ្មេញ ខ្មែរមានបណ្ឌិតប្រាជ្ញពាសពេញ បរទេសចូលចេញទិនគោរព ៗ ខ្មែរស្ដាយតែសាមគ្គីជាតិ ដែលខ្មែរធ្លាប់រក់តលើផែនភព ខ្មែរខំសាងជាតិឥតឈរឈប់ ប្រឹងតាំងថ្ងៃយប់គោរពជាតិ ៗ ខ្មែរសម័យចាស់ក្មេងទាំងប្រុសស្រី អង្គរបុរីជាតាយាទ ខ្មែរលើកមតិកត្រដាងលាត បង្ហាញខ្មែរញាតិឲ្យឃើញច្បាស់ ៗ ខ្មែរក្ដៅក្នុងចិត្តក្បិតគេត្រួត ស៊ូរកតធ្លាក់ឈាមលំបាកណាស់ ខ្មែរបង់ទឹកដីមាសប្រាក់កាស ទឹកសព្រាត់ប្រាសគ្នាយូរហើយ ៗ ខ្មែរក្នុងពេលនេះដឹងខ្លួនពិត លះបង់ជីវិតឥតស្ដាយឡើយ ខ្មែរកសាងជាតិឲ្យបានស្បើយ ខ្មែរអើយរក្សាកម្ពុជា ៗ

ខ្មែរសុំផ្ដាំខ្មែររួមលោហិត ឲ្យលះជីវិតកុំបែកគ្នា ខ្មែរខំព្យាយាមរៀនវិជ្ជា ឲ្យចេះគ្រប់គ្នាទាំងប្រុសស្រី ៗ ខ្មែរត្រូវក្លាហានយ៉ាងអង់អាច គួរលះកំណាចកាចអប្រិយ មានឫកថ្លៃថ្នូរល្អគប្បី ឲ្យកើតសិរីគ្រប់រូបអង្គ ៗ ខ្មែរជាគ្រហស្ថត្រូវគោរព ផ្ដេកគោនក្រោមម្លប់ខ្មែរព្រះសង្ឃ ខ្មែរខានបព្វជិតជួយជំរង់ ឲ្យខ្មែរដើរត្រង់ផ្លូវប្រាកដ ៗ ខ្មែរណាចិត្តខ្លាំងគួរខ្មែរទប់ ឲ្យខ្មែរនោះឈប់ដោយហ្មត់ចត់ ខ្មែរមានអាណិតខ្មែរកំសត់ ឲ្យប្រាក់កំណត់ធ្វើដើមទុនៗ ខ្មែរនាម៉ឺនអាណិតខ្មែរក្រស្ដផង កុំធាក់រាយចង់ប្រមាថគុណ ខ្មែរវែកជួយចែកឲ្យខ្មែរពុនខ្មែរកុំធំមុនចេះវិជ្ជា ៗ ខ្មែរធំចេះច្បាប់ត្រូវកោតខ្លាចកុំប្រើអំណាចហួសមហិមា ខ្មែរក្រស្រគោរពច្បាប់នានា កុំមើលងាយគ្នារក្សាវង្ស ៗ ខ្មែរៗស៊ូស្លាប់ការទឹកដី កុំបីពឹងគេទុកខ្លួនល្ងង់ ខ្មែរៗស៊ូស្លាប់ក្នុងរណរង្គ ខ្មែរកុំលះទង់ជាតិខេមរា ៗ ខ្មែរៗក្រោកឡើងតស៊ូខ្លាំង ខ្មែរកុំសំកាំងចាំខ្មោចតា ខ្មែរៗកុំដេកចាំវាសនា ខ្មែរកុំសាកផល់ណាទៀត ៗ ខ្មែរចាស់ក្រោកឡើងស្ដីគំរាម ខ្មែរក្មេងក្លាមៗឲ្យខំផ្ទៀត ខ្មែរចាស់មានប្រាជ្ញគិតរកស្ទៀត ខ្មែរក្មេងជ្រៀត

សៀតតាមបាសខ្ញុំ ៗ ខ្មែរចាស់កុំឆាន់តែដេកស្លាប់ ខ្មែរក្មេងចំណាប់កុំឆាន់យំ ខ្មែរចាស់ច្រើនចេះមន្តអាគម ខ្មែរក្មេងចូលស៊ុំកុំណាក់ធុក ៗ ខ្មែរចាស់ត្រូវធ្វើបុកអង់អាច ខ្មែរក្មេងកុំខ្លាចបាសទាំមុខ ខ្មែរចាស់រក្សាការពារស្រុក កុំឲ្យគេលុកកម្ពុជា ៗ

មហា•ឧត្តមវិជ្ជា ស្វយ-សុវណ៌

# នរកនៅឯណា?



នរក-សួគ៌ ជារឿងដែលជជែកគ្នាមកហើយ ៗ នៅជាបញ្ហាដែលជាទីកំបាំងមួយមិនទាន់ដាច់ស្រេច នរកគ្រាន់តែជាពាក្យបន្ទាច? ឬសួគ៌ជាពាក្យសរសើរបញ្ចោរ? នោះជារឿងដែលយើងត្រូវគិត ៗ គ្រប់ៗសាសនា មានការនិយាយដល់នរកដែលគួរខ្លាចគួរស្អប់ស្អែងយកគ្នាទៅវិញ ភាពរបស់សួគ៌ ជាភាពដែលសរសើរបញ្ចោរពួកមនុស្សដែលកំពុងជាតជាំដោយទុក្ខ ៗ ដូច្នេះ មានមែនឬទេ? សូមពិចារណាដោយវិចារណញ្ញាណតទៅ ៗ

រឿងនរក ជាបញ្ហាមួយដែលបានមកច្រើនតាន់

ធំហើយ សូម្បីក្នុងបច្ចុប្បន្ននេះ ក៏នៅមានមនុស្សភាគច្រើននាំយកមកជជែកគ្នាថា នរកមានមែនឬទេ? មនុស្សខ្លះជឿថាមាន ខ្លះមិនជឿ ហើយបណ្ដាមនុស្សដែលជឿ អាចបែងចែកទៅទៀតគឺ:

នរក តាមដែលមានពោលទុកក្នុងគម្ពីរមាល័យថា មានខ្ទះទង់ដែង មានដើមរកាមានបន្លា ១៦ អង្គុលិ មានផ្លែគកបំពុសដែក មានភ្នំដែលសន្ធោសន្ធៅដោយរងើកភ្លើង ។ល។ ទាំងនេះ ខ្លះជឿជាក់ថាមានពិតដូចដែលពោលនេះទាំងអស់ អ្នកខ្លះជឿដែរ តែគ្រាន់តែជឿថាជារឿងប្រៀបធៀបប៉ុណ្ណោះ ។ លោកនៃនរកពិតៗ ដែលជាលោកមួយទៀតនោះមិនមានទេ តែយ៉ាងណាក៏ដោយ មុននឹងវិនិច្ឆ័យជាពិតឬមិនពិត សូមឲ្យនឹកដល់រឿងដូចតទៅនេះសិន ។

សាសនាដែលសំខាន់ៗ គ្រប់សាសនា សុទ្ធតែមានពោលដល់រឿងនរកទាំងអស់ សូម្បីមានបរិយាយផ្សេងគ្នា តែមានបំណងដូចគ្នាគឺ: ត្រូវការបង្ខំឲ្យមនុស្សទាំងឡាយជឿថា អ្នកធ្វើបាប "ត្រូវចុះនរក" នរកតាមដែលសាសនាបានពោលទុកនោះ ជារឿងពិត ឬបញ្ឆោត ឬបន្លាច ឬជារឿងប្រៀបធៀបក៏ដោយ ក៏សុទ្ធតែមានប្រយោជន៍យ៉ាងច្រើនសម្រាប់អ្នកដែលជឿ ហើយសាស្ដាមួយអង្គៗ មានសេចក្ដីធ្លៀវធ្លាត មានចិត្តប្រកបដោយមេត្តាករុណាយ៉ាងច្រើន ពាក្យប្រៀនប្រដៅរបស់លោកមួយម៉ាត់ៗ រមែងមានប្រយោជន៍ច្រើន បើទុកជារឿងខ្លះមិនមែនជារឿងពិត ដែលគ្រាន់តែជាកលឧបាយក៏ដោយ យើងក៏មិនត្រូវតិះដៀលលោកដែរ ព្រោះថាលោកទាំងមូលត្រូវតាំងនៅដោយកលឧបាយ ដរាបណាដែលមនុស្សនៅមានអវិជ្ជា មានកិលេស ការប្រើកលឧបាយក៏ជាធម្មតាត្រូវប្រើខានមិនបាន ។ ឧបាយរបស់មនុស្សដែលមើលឃើញប្រយោជន៍ខ្លួនប៉ុណ្ណោះ ទើបយើងគួរខ្លាច ចំណែកឧបាយរបស់អ្នកប្រាជ្ញមានចិត្តខ្ពស់ រមែងមិនមានអ្វីជាពិសេស មនុស្សល្ងង់អ្នកប្រាជ្ញនឹងខ្វាយទៅគ្រោះភាពជាងមនុស្សល្ងង់ព្រមទទួលខ្លួនជាល្ងង់នឹងអ្នកប្រាជ្ញដែលមានចិត្តមេត្តាករុណាហើយប្រាជ្ញាប្រយោជន៍ឲ្យអ្នកដទៃ ។

ម្យ៉ាងទៀតនិស្ស័យរបស់មនុស្ស កាលបើបេះដូងយ៉ាងណា ក៏ច្រើនតែចូលចិត្តថា ធម្មជាតផ្សេងៗ ត្រូវដើរទៅតាមធម្មតារបស់វាតែម្យ៉ាង តាមដែលខ្លួនធ្លាប់ដឹង សន្មតថាឈ្មោះសុខ ធ្លាប់ឃើញតែដែកលិចទឹក មិនដែលឃើញកប៉ាល់ឬយន្តហោះ ហើយមិនមានការដឹងដែលទាក់ទងដល់រឿងអស់នេះផង កាលបើនិយាយដល់រឿងដែកមិនទឹក ឈ្មោះសុខគិតថា ដែកលិចទឹកជាដរាបមិនដែលមានដែកណាអណ្ដែតទឹក ឬហោះទៅលើអាកាសបានទេ បើមានគេនិយាយថា មានដែកអណ្ដែតទឹកឬហោះទៅលើអាកាស តើឈ្មោះសុខជឿឬទេ? បើតាមពិត ឈ្មោះសុខមុខជាមិនជឿដោយដាច់ខាតហើយសេចក្ដីចូលចិត្តរបស់

គាត់នោះតើយើងនឹងវិនិច្ឆ័យថាម៉េចទៅ? យើងនឹងការគាត់ឲ្យគាត់ខុសទាំងអស់ក៏មិនបាន គំនិតរបស់គាត់ត្រូវដែរតាមដែលគាត់ធ្លាប់សង្កេត តែនៅខ្លះខ្លះមិនទាន់បរិបូណ៌ប៉ុណ្ណោះ ឯមនុស្សយើងគ្រប់គ្នាក៏ដូចគ្នានឹងរឿងនេះ បើទុកជាឆ្លាតយ៉ាងណាក៏គង់តែមិនផុតពីលក្ខណៈនេះដែរ ដូច្នេះការដែលនឹងសម្រេចមតិថា នរក មានឬមិនមានក៏ត្រូវគិតដល់មាត្រាដ្ឋាននៃការចេះដឹងរបស់ខ្លួនផង ។

ម្យ៉ាងទៀត មនុស្សដែលមិនព្រមជឿ នរក បាបកម្ម ក៏មិនត្រូវមានហេតុសំខាន់ដែលទាក់ទងដល់រឿងកុហកឬពិតដែរ រឿងពិតៗដែលអ្នកដទៃក្រឡេកឃើញបានដោយងាយ មានមនុស្សខ្លះមិនជឿក៏មាន រឿងដែលបានពោលមកនេះ មានការទាក់ទងនឹងហេតុផលក្នុងផ្លូវចិត្តទៀត គឺ មនុស្សដែលមានសន្តានចិត្តចង់ធ្វើសេចក្ដីអាក្រក់ រមែងមិនចង់ឲ្យអ្នកដទៃតិះដៀលព្រោះមិនសប្បាយចិត្ត ហើយមិនចង់ឲ្យមានអ្នកជំទាស់នឹងចិត្តខ្លួន ដោយសារកលឧបាយនៃការដឹងនេះជាមូលដ្ឋាន អ្នកនោះរមែងក្រឡេកមើលឃើញតែហេតុផលដែលខ្លួនឯងយល់សមគួរថានឹងត្រូវធ្វើយ៉ាងនោះ ចំណែកហេតុផលដែលជំទាស់នឹងសេចក្ដីចេះដឹងតែមើលមិនឃើញ ឬគិតឃើញដែរតែមិនធ្វើ គួរយ៉ាងដូចពេទ្យខ្លះជក់បារី ឬ ផឹកស្រាទាំងបំពាន ដែលខ្លួនធ្លាប់ដឹងថាជាអន្តរាយដល់រាងកាយ ហើយគួរតែធ្វើខ្លួនឲ្យជាគំរូដល់អ្នកដែលមិនដឹង ។

អ្នកសិក្សាសីលធម៌ធ្វើសេចក្ដីអាក្រក់ទាំងបំពាន អ្នកចេះច្បាប់ធ្វើខុសច្បាប់ទាំងបំពាន បើមានគេទៅសួរអ្នកទាំងនេះមុខជានឹងសំដែងហេតុផលគួរស្ដាប់គួរជឿទាំងអស់ តែហេតុផលទាំងនោះ កាលបើកន្លងផុតបន្តិចទៅ ខ្លួនឯងហ្នឹងឯង ក៏គង់ចូលចិត្តបានថាជាហេតុបញ្ឆោតខ្លួនឯងនឹងអ្នកដទៃ ។ សីលធម៌ ឬសាសនា សុទ្ធតែជំទាស់ដល់ការបោកបាបរបស់មនុស្ស ដូច្នោះមនុស្សដែលមានការចេះដឹងមិនខ្ពស់មិនជួនល្ម ទើបមិនជឿ មើលមិនឃើញសេចក្ដីពិតឬប្រយោជន៍ មនុស្សខ្លះបើចេះដឹងច្រើនឆាប់រកហេតុផលបានច្រើន យកមក លុបលាងជំនឿក្នុងសាសនាបានច្រើន មានតែមនុស្សដែលមានការចេះដឹងខ្ពស់ប៉ុណ្ណោះទើបជឿហើយមើលឃើញសេចក្ដីពិតបានងាយ ព្រះសម្ពុទ្ធទ្រង់ត្រាស់ទុកថា "មនុស្សដែលមិនជឿថាមានបាប ព្រោះខ្លួនចង់ធ្វើបាប" (អបណ្ណកសូត្រ ម.ម. សាមញ្ញផលសូត្រ ទី.សី. តិក អដ្ឋ.) ហេតុផលដែលនៅជាមួយនឹងអារម្មណ៍ឬនិស្ស័យ មិនមែនជារបស់ពិត រមែងបញ្ឆោតខ្លួនឯងបាន ហេតុនេះមុននឹងជឿថានរកមានឬមិនមាន ត្រូវនឹកដល់និស្ស័យចិត្តដើមរបស់យើងជាមុនសិន ។

តែយ៉ាងណាក៏ដោយ ខ្ញុំគ្មានប្រាជ្ញានឹងរកហេតុផលយកមកបញ្ចុះបញ្ចូល ដើម្បីឲ្យអស់លោកអ្នកជឿថានរកមានទេ អស់លោកជឿឬមិនជឿនោះស្រេចនៅអស់លោក ខ្ញុំគ្រាន់តែរកហេតុផលខ្លះៗ

មកស្មើនឹងអស់លោកប៉ុណ្ណោះ ឯខ្លួនខ្ញុំ ៗ ជ្រះថ្លានឹងគោលកាឡាមសូត្រដែលព្រះពុទ្ធទ្រង់សំដែងថា “ កុំចេះតែជឿតាមតម្រាឬក្បួនខ្នាតពេក ត្រូវគិតនឹងពិចារណារកហេតុផលមើលសិន”

(នៅមានត)

---

# រឿងគួរឆ្ងល់

កូនសិស្សសួរលោកគ្រូថា ពានប្រោស! ខ្ញុំព្រះករុណារៀនសូត្រធម៌អាចចេះដឹងបន្តិចបន្តួច យល់ច្រឡំ ៗ នឹកឆ្ងល់ថា ព្រះពុទ្ធអង្គទ្រង់ទូន្មានសាវកឲ្យលែងប្រកាន់ខ្លួនប្រាណ កុំឲ្យរាប់អានរូបកាយទាំងមូលនេះថាជារបស់ខ្លួន មែនឬទេ ?

លោកគ្រូឆ្លើយ ពិតមែនហើយ លោក!

– ពានប្រោស! បើមែនដូច្នោះ ម៉េចក៏គ្រូសាមណេរទាំងអស់និយាយនឹងឧបាសកថា អាត្មា ឬអាត្មាភាពប្រែថា ខ្លួន ឬ អញ ខ្ញុំ ហ៉ើងនេះវិញ មិនផ្ទុយនឹងព្រះពុទ្ធដីកាហើយឬ ?

– មិនផ្ទុយទេ លោក! ព្រោះអាត្មា ប្រែថា ចិត្តៗ នេះជាធំលើរូបកាយទាំងមូល ៗ គេបានសុខក៏ព្រោះចិត្តល្អ គេបានទុក្ខក៏ព្រោះចិត្តអាក្រក់ ៗ បើថាតាមព្រះអភិធម្មលោកថា មិនមែនមនុស្ស មិនមែនសត្វ មិនមែនប្រុសមិនមែនស្រីទេ គឺរូបកាយនេះជាអាត្មា (ចិត្ត) តែម្យ៉ាងប៉ុណ្ណោះ ៗ ហេតុនោះ អ្នកបួសនិយាយថា អាត្មា ឬ អាត្មាភាពត្រូវហើយ មិនខុសទេ ៗ

– ពានប្រោស ! ព្រះពុទ្ធអង្គប្រាប់ថា ឲ្យយើងទីពឹងខ្លួនឯង កុំឲ្យទីពឹងអ្នកដទៃទៀយ មែនឬទេ ?

– មែនហើយលោក ៗ

– ពានប្រោស! បើមែនដូច្នោះ ម៉េចក៏ព្រះអង្គត្រាស់ថា ឲ្យយើងទទួលព្រះត្រៃសរណគមន៍ គឺឲ្យទីពឹងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មិនគឺព្រះអង្គបោកយើងទេឬ ?

– ព្រះពុទ្ធអង្គមិនបោកទេ លោក ! ទ្រង់ប្រាប់យើងត្រង់ណាស់ ព្រោះថាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គ្រាន់តែជាអារម្មណ៍ខាងក្រៅ ជាកសិណសាក្សីនៃចិត្តយើងបើចិត្តយើងអាក្រក់ ហាត់ពត់តៅតាមធម៌មិនបានទេ សូម្បីយើងលើកព្រះពុទ្ធទូលលើក្បាល ឬយើងក្រាបឱបព្រះបាទព្រះរហូតដល់ស្លាប់ ក៏មិនហៅថាអ្នកទីពឹងព្រះពុទ្ធដែរ ព្រោះចិត្តខ្លួននៅតែអាក្រក់ដដែល ៗ

– ពានប្រោស! បើដូច្នោះ យើងទីពឹងព្រះពុទ្ធតើបានប្រយោជន៍អ្វី ធ្វើឲ្យតែទៀយខ្លួនឥតអំពើ ?

– មិនឥតអំពើទេ លោក ! មានប្រយោជន៍ណាស់គឺប្រយោជន៍ត្រង់ខំធ្វើត្រាប់ព្រះពុទ្ធ ប្រឹងលះបង់ចិត្តអាក្រក់តាមលំអានព្រះពុទ្ធ ៗ ហេតុនេះយើងត្រូវចេះដឹងរឿងរ៉ាវព្រះពុទ្ធឲ្យច្បាស់លាស់ឲ្យសព្វគ្រប់ កុំចេះតែថាព្រះពុទ្ធៗតាមគេប្រាប់ត្រូវយល់ថាព្រះពុទ្ធ

នោះតើជាអ្វី, ព្រះធម៌ជាអ្វី, ព្រះសង្ឃជាអ្វី ។ ពាក្យជា ពុទ្ធ, ធម៌, សង្ឃ ទាំង ៣ ម៉ាត់នេះមានអត្ថជ្រាលជ្រៅណាស់ ឆាន់ពន្យល់លោកពេលនេះមិនបានទេ ព្រោះពេលខ្លីពេក ។

— ទានប្រោស ! ល័ទ្ធិពុទ្ធៈប្រកាន់យកកម្មផលជាធំមែនឬទេ ?

— មែនហើយ លោក !

— ទានប្រោស ! បើមែនដូច្នោះ ម៉េចក៏យើងទៅសូត្រមន្តឲ្យបាសកថា ការពារអន្តរាយខ្លះ, រំដោះគ្រោះខ្លះ, ចំរើនអាយុទីឃសសក្តិលាភសក្ការៈខ្លះ មិនគឺយើងធ្វើផ្ទុយនឹងល័ទ្ធិពុទ្ធៈហើយឬ?

— មិនផ្ទុយទេ លោក! ដែលយើងសូត្រមន្តឲ្យបាសកនោះ គ្រាន់តែធ្វើឲ្យជាអារម្មណ៍ខាងក្រៅឬជាគ្រឿងរំលឹកស្មារតីគេប៉ុណ្ណោះទេ ឯការល្អអាក្រក់ស្រេចលើចិត្តអ្នកស្តាប់មន្ត បើគេតាំងចិត្តលះអាក្រក់ចេញ មុខជាគេបានល្អបានសុខ ប្រៀបដូចចោរម្នាក់ទើបរួចពីគុកគេនិមន្តលោកទៅសូត្រមន្តរំដោះគ្រោះជាកុំឲ្យគេជាប់គុកទៀត ដល់ថ្ងៃក្រោយអ្នកនោះមិនលួចគេទេ បែរជាខឹងឈ្លោះគ្នាសម្លាប់អ្នកឯទៀតទៅវិញតុលាការកាត់ទោសប្រហារជីវិត តើមន្តដែលយើងសូត្រឲ្យគេនោះការពារជីវិតគេបានដែរឬទេ ?

—ទានប្រោស! ការពារមិនបានទេ ។

—អើ! ហ្នឹងហើយ ដែលឆាន់ប្រាប់លោកថា ល័ទ្ធិពុទ្ធៈឲ្យកាន់កម្មផលជាធំបំផុត ។

—ទានប្រោស! ចុះកម្មផលនោះតើនៅត្រង់ណា ?

—នៅត្រង់ចិត្ត ។ បើចិត្តអាក្រក់ធ្វើអំពើអាក្រក់ ហើយមុខជាបានទុក្ខជាផល ។ បើចិត្តល្អធ្វើអំពើល្អ ហើយមុខជាបានសុខជាផល ។

—ទានប្រោស! បើល័ទ្ធិពុទ្ធៈប្រកាន់ចិត្តឬកម្មផលជាធំបណ្តាច់ដូច្នោះ ខ្ញុំព្រះករុណាសូមថ្វាយបង្គំលាព្រះគុណម្ចាស់ទៅនៅបាតក្ដឹកពាយហើយ នៅតែម្នាក់ឯង កុំឲ្យមានគ្នីគ្នាដើម្បីនឹងលះចិត្តអាក្រក់ចោល ធ្វើចិត្តល្អឲ្យកើតឡើង ។

— ចុះបើលោកទៅហើយ ចិត្តអាក្រក់លោកផ្ញើទុកលើអ្នកណា ?

— ទានប្រោស ! ផ្ញើលើគេមិនបានទេ ចិត្តអាក្រក់ជាប់នឹងខ្ញុំព្រះករុណាទៅដែរ ។

— ចុះទៅបាតក្ដឹកពាយនោះ មានចិត្តល្អគេគរទុកទាំងគំនរៗទៅឬអី ?

— ទានប្រោស ! គ្មានទេ ។

— ចុះលោកទៅរកចិត្តល្អបានពីណា ?

— ទានប្រោស ! បានពីខ្លួនខ្ញុំព្រះករុណា ។

— បើដូច្នោះ ឆាន់ទាយឲ្យលោកថា លោករកចិត្តល្អមិនបានទេមុខជាចិត្តលោករឹតតែអាក្រក់ជាងឥឡូវនេះទៀត ព្រោះរាជការចាប់លោកដាក់គុក ត្រង់ល្មើសព្រះរាជបញ្ញត្តិដែលហាមប្រាមមិនឲ្យអ្នកណានៅក្នុងព្រៃ ឬក៏ម្នាក់ឯង ។ លោកបែរជាខឹងថាធម៌មិនជួយលោកវិញនេះជាចិត្តអាក្រក់ ។

- បាទប្រោស! បើដូច្នោះ ឲ្យខ្ញុំព្រះករុណាធ្វើដូចម្ដេចទៅវិញ ?

- លោកស្ដាប់ចាន! ត្រូវលោកនៅជួយធ្វើការធាន់ ព្រោះលោកចេះធម៌អាថ៌វិន័យសិក្ខាក៏ច្រើន ចេះភាសាបាលី, សំស្ក្រឹត, បារាំង, អង់គ្លេសក៏ជ្រៅជ្រះ បើលោកជួយធ្វើការធាន់នឹងកើតផលប្រយោជន៍ធំទូលាយណាស់ ។

- បាទប្រោស! តែគង់អ្នកបួសព្រះពុទ្ធប្រាប់ឲ្យលះបង់ការងារឲ្យលះបង់ផលប្រយោជន៍មែនឬទេ ?

- មែនហើយលោក! ប៉ុន្តែលះបង់ដោយយ៉ាងការងាររបស់គ្រហស្ថដូចជាធ្វើស្រែចំការជួញប្រែជាដើម អ្នកបួសធ្វើមិនបានទេ ប៉ុន្តែផលប្រយោជន៍ផ្ទាល់ខ្លួនគឺមគ្គផលអ្នកបួសត្រូវតែស្វែងរកខានមិនបាន ។ ដែលឲ្យលោកជួយធ្វើការធាន់នេះ គឺការគង់ព្រះពុទ្ធសាសនា ឲ្យលោកជួយផ្សាយព្រះពុទ្ធសាសនាទៅនានាប្រទេស ដោយភាសាបារាំងឬអង់គ្លេស ព្រោះគេមិនចេះភាសាខ្មែរ ។ ដែលធាន់ថានឹងកើតផលប្រយោជន៍ធំទូលាយនោះគឺថា បើព្រះពុទ្ធសាសនាផ្សាយទៅដល់ស្រុកណា អ្នកស្រុកនោះនឹងបានសុខបានចំរើនដោយសារពន្លឺរស្មីនៃធម៌អាថ៌គង់ពុទ្ធសាសនា ។ ហេតុនេះបានជានៅលង្កាទ្វីបគេផ្ដើមធ្វើសមាគមពុទ្ធសាសនាពិភពលោក ។ នៅប្រទេសកម្ពុជាក៏ធ្វើសមាគមពុទ្ធសាសនាដែរគឺហៅថា ពុទ្ធិកសមាគម ១ មិត្តសាលាបាលី ១ ។ នៅប្រទេសកម្ពុជាក្រោមក៏មានសមាគមពុទ្ធសាសនាដែរ ។ អ្នកមេគំនិតផ្ដើមធ្វើសមាគមទាំងនេះ សុទ្ធតែប្រកបដោយចិត្តមេត្តាចង់ជួយមហាជនឲ្យរួចពីទុក្ខ ឲ្យផុតពីចម្បាំងកាំផល់ ឈ្មោះថាខំធ្វើតាមលំអាននៃព្រះអរហន្តជាន់ដើមដែលលោកប្រកាសផ្សាយពុទ្ធសាសនាដូចមានសេចក្ដីពិស្ដារក្នុងគម្ពីរមហាវង្សស្រាប់ ។

- បាទប្រោស! ខ្ញុំព្រះករុណាអស់ឆ្ងល់ហើយ សូមនៅគាល់បំរើជួយធ្វើការផ្សាយព្រះពុទ្ធសាសនាព្រះគុណម្ចាស់តទៅ ។ សូមបាទថ្វាយបង្គំលាទៅកុដិវិញ ។

ចប់

ញ៉ូ-ញូ

## បញ្ហាពោលអំពីមនុស្សស្បែកខ្មៅ

(តពីលេខ ៩ មក)



ការប្រឡះគ្រាប់កប្បាសចេញពីសំឡី បានបង្កើនឲ្យមានពាក្យសុំទិញកប្បាសយ៉ាងច្រើន ។ សិប្បការដ៏ធំខាងកប្បាសរមែងចំរើនឡើងជាខ្លាំង ក្នុងភាគនៃប្រទេសនោះ

ម្ល៉ោះហើយកប្បាសទៅជាដំណាំលេខមួយក្នុងតំបន់ទិសទក្សិណ ។

ក្នុងសម័យនោះ ម៉ាស៊ីនសំរាប់ដាំសំរាប់ភ្ជួររាស់ សំរាប់ប្រមូលកប្បាសនៅមិនទាន់មាននៅឡើយ ។ ដូច្នេះត្រូវតែរកចំនួនមនុស្ស ឲ្យកាន់តែច្រើនឡើងៗ ដើម្បីដាំនិងដើម្បីបេះកប្បាស ក្នុងគ្រួសារមួយៗ ត្រូវមានទាសកម្មកររហូតដល់ទៅ ២០០០ ឬ ៣០០០ នាក់ ។ មានទាសកម្មករពួកច្រើនត្រូវគេចិញ្ចឹមដោយស្រួលឲ្យដេកនៅក្នុងទីល្អ, ស្លៀកពាក់ល្អ ព្រមទាំងមានគេថែរក្សាពេតឲ្យទៀតផង ។

ពួកស្បែកខ្មៅទាំងនោះ គេយកមកបង្ហាត់ឲ្យរៀនធ្វើស្រែចំការ, ពួកខ្លះឲ្យធ្វើការផ្ទះ, ហើយពួកខ្លះទៀតទៅជាជាងឈើ, ជាជាងរៀបអិដ្ឋ, ជាជាងដែក ។ល។ ប៉ុន្តែជាទុកល់ គេមិនសូវបង្ហាត់គាត់ឲ្យចេះដឹងខាងអក្សរសាស្ត្រឡើយ, ក្នុងរដ្ឋពួកខ្លះមានបង្កើតច្បាប់ហាមផ្តាច់មិនឲ្យបង្រៀនអាន និងបង្រៀនសរសេរដល់ទាសកម្មករណាមួយឡើយ ។

ដោយសារតែមានអ្នកធ្វើការស៊ីឈ្នួលហោកដើម្បីផ្តល់នូវគ្រឿងឧបភោគនិងបរិភោគ ដែលគេត្រូវការយ៉ាងច្រើនបានជារដ្ឋទាំងឡាយខាងទិសទក្សិណបានមានសេចក្តីចំរើនឡើងៗ ដោយសារស្ថានការណ៍ខាងលើនេះ ទើបគេឃើញកើតមានត្រកូលអភិជនយ៉ាងកើតប្រកបដោយស្ត្រីមានរូបល្អ និងបុរសមានប្រាជ្ញាដ៏វៀងវៃ ៗ អ្នកជំនាញការសំខាន់ៗទាំងឡាយនៃប្រ-ទេសដែលមាននាមកត់ត្រាទុកពេញទាំងទំព័រនៃប្រវត្តិសាស្ត្ររបស់សហរដ្ឋអាមេរិកសុទ្ធសឹងចេញមកពីត្រកូលអភិជនខាងលើនេះ ។

ពិតមែនជាទាសភាពបានកើតមានឡើងហើយដោយពេល, ដោយខណៈក្នុងតំបន់ទាំងអស់នៃពិភពលោក ហើយថែមទាំងក្នុងសព្វថ្ងៃនេះក៏នៅកើតមានរាំងរែប្រជាខ្លះ ទើបមានសំឡេងបន្ទរឡើងប្រឆាំងនឹងកិច្ចប្រតិបត្តិខាងលើនេះ ដោយចោទប្រកាន់ថាជាកិច្ចប្រតិបត្តិផ្ទុយនឹងជំនឿខាងសាសនានៃសហរដ្ឋ-អាមេរិក ព្រមទាំងផ្ទុយនឹងគោលច្បាប់នៃលទ្ធិប្រជាធិបតេយ្យដែលជាមូលដ្ឋានកំណើតនៃមនុស្សជាតិ ។ សេចក្តីប្រកាសនៃឯករាជ្យ បានថ្លែងចំពោះសាកលលោកថា មនុស្សទាំងអស់សុទ្ធតែកើតមកប្រកបដោយសមភាព និងមានសិទ្ធិពេញលេញចំពោះកិច្ចប្រតិបត្តិទាំងឡាយគឺការរស់នៅ, ការសេរីភាព និងការស្វែងរកនូវសេចក្តីសុខ ។

ក្នុងឆ្នាំ ១៨០៨ យុវជនជាតិសហរដ្ឋអាមេរិកបានហាមផ្តាច់មិនឲ្យមានការនាំខ្ញុំកំដរជាតិអាហ្វ្រិកចូលមកជាថ្មីឡើយ ពួកទាសកម្មករដែលបានតាំងនៅរួចហើយ ក្នុងប្រទេសរមែងចំរើនតៗមកដោយចំនួន និងដោយការសំខាន់ខាងផ្លូវសេដ្ឋកិច្ច មានជនជាច្រើនខាងទិសឧត្តរនិងខាងទក្សិណ បានសំដែងមតិប្រឆាំងនឹងបទមានទាសភាព ប៉ុន្តែសេចក្តីតក៏ដោយគាត

ច្រើនមកពីខាងទិសឧត្តរ ដោយរដ្ឋដែលសេដ្ឋកិច្ចមិនបាន
ពឹងផ្អែកទៅលើការហត្ថកម្មមានឈ្នួលថោក ។

ដូច្នេះនៅពេលជាប្រថមនៃប្រវត្តិសាស្ត្ររបស់
ស្រុក មានការខ្វែងគំនិតគ្នាបានផ្តើមកើតឡើងដែល
បណ្តាលឲ្យមានរដ្ឋប្រហារអស់រយៈពេល ៤ ឆ្នាំទៅ
បណ្តារដ្ឋទាំងឡាយគឺពីឆ្នាំ១៨៦១ ទៅ១៨៦៥ ។ ក្នុង
សម័យកំពុងកើតសង្គ្រាមពេញទី លោកអាប្រាហាំ
ឡាំងកុលជាប្រធានាធិបតីនៃសហរដ្ឋអាមេរិកបាន
ផ្សាយនូវសេចក្តីប្រកាសមួយ បំបាត់មិនឲ្យមានទាស-
ភាពក្នុងពេលដែលកំពុងកើតចលាចល ។ តមក
ក្នុងពេលក្រោយការកែប្រែជាបីក្នុងច្បាប់រដ្ឋធម្មនុញ្ញ
បានធានាអះអាងឲ្យមានសិទ្ធិស្មើគ្នាដល់មនុស្សទាំង-
ឡាយទូទៅមិនគិតពីជាតិពីសាសនា ឬពីលក្ខណៈ
ជាទាសភាពដែលមានមកហើយក្នុងអតីតកាល ។
ដូច្នេះទាសភាពក៏បានវិនាសចេញស្រឡះពីសហរដ្ឋ
អាមេរិករហូតមក ។

ប៉ុន្តែអង្គការច្បាប់គឺមិនងាយនឹងរំលុបរំលាងឲ្យ
បាត់ទោសកំហុសខាងលើនេះឲ្យអស់ឡើយ ។ ទាស-
ភាពបានត្រឡប់ទាមទារឲ្យមានសេរីភាពរបស់ខ្លួន
ឡើងវិញក៏ពិតមែន ប៉ុន្តែសមភាពខាងសេដ្ឋកិច្ចនឹង
ខាង

(មានត)

# ដំបូន្មាន កាព្យពាក្យ ៧

ឯកភព្វច្រើនដោយអក្សរជាតិ គួរយើងខំឃាត
រៀនឲ្យសព្វ ឲ្យបានចេះច្រើន៣-៤ជប់ ត្រូវឲ្យចេះ
សព្វគ្រប់វិជ្ជា ។ កិច្ចការណាផ្ទាល់នឹងជាតិខ្មែរ ត្រូវ
តែសរសេរជាខេមរា ម្យ៉ាងជាតិយើងខ្វះគ្មានវ៉ែនតា
ឬខ្វះកណ្ណាស្តាប់ពុំបាន ។ កុំស៊ីសាច់ឈាមជាតិ
ដូចគ្នា ឃើញជាតិវេទនាគួរប្រោះប្រាណ ត្រូវ
ប្រាប់ប្រយោជន៍កុំបិទខាន យើងចេះប៉ុន្មានកុំលាក់ទុក
កុំលេងបៀរប៉ោផ្គុំគាត់ ដែលចាត់ជាផ្លូវអបាយមុខ
នាំខូចទ្រព្យធនខ្លួនជាប់គុក កើតទុក្ខដោយសារការ
លេងល្បែង ។ កុំប្រកាន់យសហួសតម្រា ទៅទី
ឋានណាគួរគោរពក្រែង កុំធ្វើបំពានតាមចិត្តឯង
ច្បាប់ព្រៃត្រូវលែងលះឲ្យដាច់ ។ កុំបីខ្ចីពឹងដង្ហើមគេ
ត្រូវខិរិះរេឲ្យចំណាប់ កុំដេកបនព្រះទាល់ប្រាណ
ស្លាប់ ប្រញាប់ងាកមើលជុំវិញប្រាណ ។ កុំ
សេពនឹងជនអកតញ្ញូ កុំសេពនឹងគ្រូឥតចំណាន
កុំទុកចិត្តជនពាលកុម្មហាន បើចង់ច្រើនថ្កានត្រូវផ្គង់
បុទ្ធ៍ ។ កុំប្រព្រឹត្តស្រា-ស្រី-និងល្បែង គួរលះ
គួរលែងកុំប្រព្រឹត្ត ព្រោះនាំឲ្យខូចពិតផលចិត្ត វិប-
រិតផ្តេសផ្តាសក្នុងលោកិយ ។ កុំជាប់ចិត្តស្រានឹង
ការល្បែង គួរលះគួរលែងបានមិនអី ឯគ្រង់ចំ-
ណង់ចង់នឹងស្រី លោកិយលះបានដោយកម្រ ។
កុំឈ្លក់ខ្លួនជ្រុលពុលនឹងលាភ កាន់ចិត្តសុភាព

ដោយស្មោះសរ កុំបំភ្លេចចុះលុះលោភធម៌ កាន់ចិត្តឲ្យល្អនឹងមិត្តភក្តិ ។ កុំកាន់បក្សខ្លួនហួសក្បួនខ្នាត កុំហ៊ានប្រមាថចាស់ព្រឹទ្ធា ជួបសង្ឃឬវត្តត្រូវវន្ទា ជាតិជាមួយគ្នាគួរមេត្តា ។ កុំអួតថាឯងចេះជាងគេ កុំធ្វើវៀចវេរនឹងកិច្ចការ កុំធ្វើអីចោលពិចារណា ទើបបានហៅថាប្រាជ្ញចេះវៃ ។ កុំថ្កោលទោសគេពុំពិនិត្យ កុំគិតខ្លួនឯងថាប្រពៃ កុំធ្វេសប្រហែសពាក្យសំដី នាំឲ្យមានភ័យកល់វេលា ។

កុំដេកសង្ឃឹមស៊ីបុណ្យព្រេង ក្រែងរលីងនេងគង់គ្រឹហា ត្រូវតែខំរៀនសព្វវិជ្ជា ស្វែងរកទ្រព្យកុំបន់ព្រះ កុំកាប់បំពង់រង់ទឹកភ្លៀង ធុរៈណាទៀងត្រូវកុំលះ រៀនសូត្រត្រូវកុំចោលមានៈ មានតេជះកុំលះចោលមិត្តភក្ដិ ។ កុំដេកទ្រមក់លក់ហួសខ្នាត ត្រូវខំសង្វាតរៀនវិជ្ជា បើយើងប្រឹងប្រែងតាំងអស់គ្នា ដែនកម្ពុជាគង់នឹងចំរើន ។ កុំបើកោងកាចកេងហួសក្រិត្យ ត្រូវតែកាន់ចិត្តឲ្យល្អទៀង ព្រួតគ្នាការពារលើកដំកើង កសាងជាតិយើងឲ្យថ្លៃថ្នូរ ។ កុំស្អប់ជាតិខ្មែរស្នេហ៍ជាតិគេ ត្រូវគិតរិះរេឲ្យហេហូរ ។ ព្រោះជាតិយើងក្រមិនសំបូរ ត្រូវយើងអាស្រ័យតាមបែបបទ ។ កុំស្អប់កុំខ្ពើមត្រង់ការត្រូវ បើយើងមិនស្គាល់ចេះប្រាកដ ត្រូវសាកសួរគេឲ្យហ្មត់ចត់ បិទមាត់មិនបានជាការអ្វី ។ កុំខ្វាក់ចង់ខ្ពស់ពាក់យសស័ក្ដិ ខ្លួនគ្មានមាសប្រាក់ធ្វើសេដ្ឋី ទៅធ្វើជាប្រាជ្ញប្រុសធ្វើស្រី កាចញាំងផែនដីត្រឡប់ឆ្ងាយ ។ កុំលះបង់ចោលនូវកិច្ចការ ត្រូវចេះរក្សាទ្រព្យសម្បាយ កុំចាយត្បិតត្បៀតឬខ្ជះខ្ជាយ មិត្តល្អបើមកយស្ទួនជាគ្នា ។

ត្រូវប្រឹងប្រែងធ្វើជាពាណិជ្ជ កុំគេចឲ្យខ្លួនក្រទ្រព្យ ត្រូវខំខ្នះខ្នែងតាំងអស់គ្នា អាចជួយភាពឲ្យថ្លៃថ្លា ។ ត្រូវដោះទូករលៀនកុំឲ្យលិច ត្បិតពេជ្ររឹងមុតគង់ប្រេះធា ត្រូវស្ងាត់ប្រយ័ត្នបញ្ជាក់ថា គិតអាថ៌ឯណាកុំអាងផិត ។ ត្រូវចេះឲ្យសព្វគ្រប់វិជ្ជា ទៅទីនានាគួរកាន់ក្រិត្យ ត្រូវតែកាន់ច្បាប់តាមកំរិត មិនត្រូវតាំងចិត្តឲ្យរវើល ។ ត្រូវខំធ្វើការសព្វសារពើ កុំបើទៅធ្វើជាអ្នកខ្ជិល ត្រូវខាត់សំអាតសព្វមន្ទិល ផងពាលតែងវិលសឹកជួបទៅ ។ ត្រូវតែកប់អានជាតិផងគ្នា ខំរៀនវិជ្ជាបំបាត់ទៅ ត្រូវលះទុច្ចរិតគ្រឿងហ្នឹងសៅ អ្នកក្រៅជួយទុកចាត់ជាញាតិ ។ ត្រូវខំបណ្ដុះឆន្ទៈសាមគ្គី ដើម្បីជាទីស្រោចស្រង់ជាតិ ត្រូវចងបាច់គ្នាកុំរាំង ក្រោកឡើងសាងជាតិដោយស័ក្ដិស្មោះ ។ ត្រូវសាងវិជ្ជាណាដែលខ្វះ រហ័សកុំបង្អង់ឲ្យសោះ ត្រូវកុំសង្ឃឹមគេតាំងអស់ ឬគិតប្រណោះបុកតំឡៅ ។ ត្រូវក្រោកពីលក់ដោយម៉ឺម៉ា រៀនសូត្រវិជ្ជាកុំឲ្យឆៅ ត្រូវគ្រប់ពាក្យចាស់លោកប្រដៅ តែនៅមិនឆ្ងាយជាងណាខ្លះ ។

ឯជនលក់ជាតិ និងសាសនា ព្រមទាំងចេស្ដាមហាក្សត្រថៃ ស៊ីទៅខាំគេគត់កៃ គួរក្បួយរស់នៅតប្រយប្រាណ ។ វិជ្ជាវិសេសលើសទ្រព្យធន

ទោះមិនអាចប្អូនឆក់យកបាន រឺផ្កាគ្មានថ្លៃនឹងប្រមាណ
ប្រើចេះតែបានគ្រប់ពេលអើយ ៗ

ព្រះសមុហ៍ សៅ-ចេស

## សន្និសីទព្រះតេជព្រះគុណពោធិវង្ស

(តពីលេខ ៩ មក)

មានការរៀបចំយ៉ាងឆើតឆាយ គេស្មានបានថាទីនោះនឹងទៅជាទីក្រុងមួយធំ ក្នុងពេលដ៏ខ្លីនេះ តែចំពោះ,



រោងឧស្សាហកម្មដែលត្រូវគ្រាប់បែកបរមាណូ

រោងឧស្សាហកម្ម១ដែលគ្រាប់បែកបរមាណូធ្លាក់ គេ-មិនឲ្យរុះរើទេ គេបានបិទប្រកាសមួយដាក់ថា (មនុស្សវិរិយបរមាណូ) គេឃើញជនជាតិជប៉ុនតាំងចាស់តាំង



កន្លែងបិទប្រកាស

ក្មេងធ្វើការគ្មានសំរាក ឲ្យតែដល់កន្លែងណាមួយ ការងារក៏ត្រូវតែចាប់កាន់ធ្វើភ្លាមមិនឲ្យយឺត នេះជាទម្លាប់ជនជាតិជប៉ុន ៗ



ប្រាសាទបូរាណនៅប្រទេសជប៉ុន

ម៉ោង ២, ៤៥ រទេះភ្លើងចេញពី ហិរោជិម៉ា ម៉ោង៨យប់ដល់ ហិមេជិ (HimeJi) ដែលជាក្រុងមួយដ៏ល្អ ចេញពីក្រុង (Himeji) ឆ្ពោះទៅកាន់ទិសកាគាម ផ្លូវបានឃើញទីក្រុងផ្សេង ៗ ជាច្រើនរហូតដល់ទីក្រុងកូបេ (Cobé) ដែលជាទីក្រុងធំទី ២ ពីតូក្យូ ចេញពីអាសកាសំដៅក្យូតូ ចូលទៅសម្រាកក្នុងគ្រឹះស្ថានមួយបានមួយស្របក់ តពីនោះគេនាំទៅមើលទីវត្តអារាមនឹងទីផ្សារស្ទើរគ្រប់កន្លែង ព្រឹកឡើងម៉ោង ៨ ចេញពីក្យូតូទៅកាន់ក្រុង ណាគូយ៉ា (Nagoya) ដោយរថភ្លើង, ម៉ោង ១១ ជាងបន្តិចដល់ក្រុង **Nagoya** គេឃើញមានការរៀបចំទទួលដោយក្មេងក្រែ១វង់ ការប្រជុំមានដូចធម្មតា តែពេលនេះ ត្រូវខ្ញុំ (ព្រះពោធិវង្ស) ធ្វើប្រធានលោកធម៌វិរៈជាអ្នកថ្លែងសេចក្ដីជំនួស ៗ

ក្នុងវេលាយប់ថ្ងៃទី ១៧ យើងត្រូវចេញដំណើរតាមរថភ្លើង នៅលើរថភ្លើងតាំងពីម៉ោង ១០,៤០ រហូតដល់ម៉ោង ៧កន្លះ ថ្ងៃទី១៨ ដល់ក្រុងតូក្យូវិញ តាមទំនងនេះរថភ្លើងធ្វើដំណើរ ពីក្រុងណាគូយ៉ាដល់តូក្យូអស់រយៈពេល ៨ ម៉ោង ។

ថ្ងៃទី ២១ មេសា-៥៤ ម៉ោង ៤ រសៀលទៅប្រជុំនៅកំពង់អគារសភារហូតដល់ម៉ោង ៧ កន្លះយប់ ។

ថ្ងៃ២២-៤-៥៤ម៉ោង ៩ ព្រឹកប្រជុំនៅកំពង់អគារសភារហូតដល់ម៉ោង ១១; រសៀលម៉ោង ១១ ទៅប្រជុំនៅសាលហ៊ីប៊ីយ៉ា មានចំនួនមនុស្សជាច្រើន ម៉ោង ៥ ខ្វះ ១៥ បញ្ចប់ការប្រជុំ ។

សន្និសីទពោលដោយសង្ខេបចប់ត្រឹមប៉ុណ្ណេះ



ប្រតិភូខាងឈរនៅមុខទីប្រជុំមួយ

### ៥–អំពីលទ្ធផលនៃការប្រជុំសន្និសីទ

តាមអត្ថបទដែលបានដាក់ឲ្យគណៈប្រតិភូជំនុំ ជាកិច្ចបញ្ចប់មហាសន្និបាតសន្តិជននាក្រុងតូក្យូ មានសេចក្ដីដូចតទៅ ៖

១-បំបាត់កុំឲ្យមានគ្រឿងអាវុធយុទ្ធភណ្ឌដែលមានកំលាំងក្រៃលែង មានគ្រាប់បែកបរមាណូនិងហ៊ីដ្រូហ្សែនព្រមទាំងល្បង

២–គ្រាប់បែកដែលធ្វើហើយសុំឲ្យរំលាយចោល

៣–សុំឲ្យរើគំនិតធ្វើកម្លាំងបរមាណូឲ្យកើតប្រយោជន៍ដល់មនុស្សលោកវិញ

៤– សូមឲ្យចំបាំងនៅឥណ្ឌូចិនចប់ដោយរហ័ស

៥– សូមកុំឲ្យមានសេនាទ័ពបរទេសនៅក្នុងឥណ្ឌូចិនទុកឲ្យឥណ្ឌូចិនមានឥស្សរភាពគ្រប់គ្រងខ្លួនឯង

៦ សុំឲ្យមាតាបិតាគ្រូបង្កើតការអប់រំកូននិងសិស្សឲ្យឈប់លេងល្បែងចំបាំង ឲ្យមានល្បែងអប់រំបង្កើនសតិបញ្ញា

៧–អប់រំក្មេងៗឲ្យមានចិត្តល្អស្រឡាញ់សន្តិភាព

៨- ការពារកុំឲ្យមានការឃោសនាបង្កើតចំបាំង

៩–រៀបចំអង្គការសន្និសីទនៅអាស៊ី កុំឲ្យជាតិអាស៊ីធ្វើសង្គ្រាមគ្នាឯង

១០– អប់រំស្រីៗឲ្យមានអំណារទទួលខុសត្រូវទំនាស់នឹងសង្គ្រាម

១១- ឃោសនាឲ្យមនុស្សមានចិត្តទំនាស់នឹងសង្គ្រាម

១២- ការពារកុំឲ្យមានចក្រពត្តិនិយម

១៣–សៀវភៅ, កាសែត, ទស្សនាវដ្ដី, កុន, វិទ្យុ និងគ្រឿងផ្សេងៗត្រូវតែនិយាយពីសីលធម៌អហឹង្សា ដែលទំនាស់គ្នានឹងសង្គ្រាមដើម្បីអប់រំយុវជន

ទឹងពួកក្មេងៗឲ្យស្រឡាញ់សន្តិភាព ចំនាស់ទឹងសង្គ្រាម ។ ដល់ប្រជុំរួចហើយ សារុបសេចក្តីនៃការនោះ បានព្រមព្រៀងគ្នាសម្រេច ។

១. បំបាត់កុំឲ្យកើតមានសង្គ្រាមក្នុងលោកតទៅទៀត ព្រោះសង្គ្រាមជាអំពើនាំឲ្យមនុស្សលោកបានសេចក្តីវិនាសគ្រប់យ៉ាង មានវិនាសជីវិតទឹងវិនាសទ្រព្យសម្បត្តិជាដើម ។

២. បំបាត់កុំឲ្យមានគ្រឿងសាស្ត្រាវុធយុទ្ធភ័ណ្ឌដែលមានកម្លាំងក្រៃលែង មានគ្រាប់បែកបរមាណូជាដើមដែលកើតឡើងដោយវិទ្យាសាស្ត្រ ព្រោះជាគ្រឿងបំផ្លាញមនុស្សឲ្យវិនាសយ៉ាងសម្បើម ។

ចម្បាំងក្តីគ្រាប់បែកបរមាណូក្តី សុទ្ធតែឲ្យផលអាក្រក់ ជួយគ្នាស្រឡះពីសេចក្តីប្រាថ្នារបស់មនុស្សក្នុងលោក ។

សេចក្តីសម្រេចទាំងនេះ គណៈកម្មការចាត់ការបានធ្វើសេចក្តីកត់ហេតុបញ្ជូនទៅអង្គការសហប្រជាជាតិសុំឲ្យបានសម្រេចតាមអង្គការខាងលើនេះ ។

អំពីកិច្ចការផ្សេង ៗ ក្រោយពេលប្រជុំ

តពីថ្ងៃទី២២មេសាមករហូតដល់ថ្ងៃទី ៨ ឧសភា គណៈបានទៅសង្កេតមើលវិទ្យាល័យ, មហាវិទ្យាល័យផ្សេង ៗ ខាងព្រះពុទ្ធសាសនា ព្រមទាំងដើរមើលបូរាណដ្ឋានក្នុងទីដំបន់ផ្សេងៗនៅក្នុងប្រទេសជប៉ុន ។ មានពេលខ្លះបានទៅជួបទឹងឥស្សរជនជប៉ុនខ្លះ ហើយបានប្រាស្រ័យចំពោះការទាក់ទងរវាងជប៉ុនទឹងកម្ពុជាខាងផ្លូវព្រះពុទ្ធសាសនា ។ល។

ចប់ដោយសង្ខេប

# អសោកមហារាជ

តពីលេខ៥មក

ជាមានធម៌សប្បុរសប្រតិបត្តិទសពិធរាជធម៌ បរិបូណ៌ដោយសីលាចារ មានព្រះរាជសទ្ធាជាតិយោភាព ទ្រង់ជំកល់ព្រះអង្គជាអគ្គសាសនូបត្ថម្ភក៍ ទ្រង់បានចារឹកគោលពុទ្ធសាសនាទុកក្នុងផែនសិលា ទុកជាបូជនីយវត្ថុដល់ប្រជាជនទាំងពួង ហើយទ្រង់សំដែងហេតុដែលនាំឲ្យព្រះអង្គឈ្វេងយល់ត្រូវតាមគោលព្រះពុទ្ធសាសនា ដាក់ក្នុងសិលាចារឹកទី១៣ ។ ក្នុងសិលាចារឹកទី១៣នេះ ព្រះអង្គទ្រង់ប្រកាសថា “ជ័យជំនះដ៏ពិតប្រាកដនោះ គឺការឈ្នះចិត្តនៃនរជនដោយធម៌ ចាត់ថាជាជ័យជំនះដែលឋិតនៅជាស្ថាពរ ស្ងប់ស្ងៀមជីវិតស្លាប់បាត់បង់ទៅហើយ (ក៏ជ័យជំនះនេះអាចតាំងនៅប្រាកដដល់មិត្តរួមលោកទាំងឡាយមិនសាបសូន្យទៅឡើយ) ។ នេះគឺព្រះរាជឱង្ការនៃព្រះបាទធម្មាសោក ដែលទ្រង់ព្រះរាជបញ្ជាឲ្យព្រះរាជបុត្រទឹងព្រះរាជនត្តាទាំងឡាយ កាន់យកជាឧត្តមគតិតទៅអនាគត “ប្រសិនបើជ័យជំនះដោយកម្លាំងសាស្ត្រាវុធតម្បៀមកដល់ ក៏ចូរឲ្យមានសេចក្តីអត់សង្កត់ ហើយស្ងប់ស្ងៀម ដើម្បីសេចក្តីត្រេកអរក្សាន្តនៃចិត្តប្រព្រឹត្តទៅក្នុងលោកនេះទឹងលោកខាងមុខ” ។

ក្នុងឋានៈជាអគ្គសាសនូបត្ថម្ភក៍ គ្រាដំបូង ព្រះបាទស្រីធម្មាសោករាជ ទ្រង់ព្រះរាជបញ្ជាឲ្យក្មាត់ការរាជការបុគ្គលិក ប្រើភាសារបស់ព្រះពុទ្ធជាផ្លូវការ ហើយទ្រង់ចេញព្រះរាជក្រឹត្យបញ្ញត្តដល់ពួកបុគ្គលិក-

រាជការនិងរាជបរិពារទាំងអស់ ឲ្យមានការរាំងប្រយ័ត្ន ខ្លួនកុំឲ្យធ្វើអំពើទុច្ចរិតដែលកើតអំពីសេចក្ដីឫស្សាជាដើម ព្រមទាំងមិនឲ្យបណ្ដែតបណ្ដោយ ក្នុងកិច្ចដែលជាខាងធំទាំងតូច ៗ ព្រះអង្គទ្រង់លើកព្រះពុទ្ធសាសនាថាជាសាសនាសម្រាប់រដ្ឋរបស់ព្រះអង្គ ដោយមានការ ៥ យ៉ាងគឺ៖ ឲ្យមានការប្រជុំធ្វើសង្គាយនាព្រះធម្មវិនិយ ១ ឲ្យចារឹកគោលពុទ្ធសាសនប្រកាសគោលធម៌ក្នុងផែនសិលា ១ ឲ្យតាំងកងសម្រាប់រក្សាសេចក្ដីបរិសុទ្ធិនៃធម៌ ១ ទ្រង់ចាត់តាំងសមណទូតឲ្យទៅប្រកាសព្រះពុទ្ធសាសនាក្នុងនានាប្រទេស ១ ទី៥ ទ្រង់ឲ្យជម្រះព្រះបាលីដែលពិតប្រាកដចារឹកទុកក្នុងផែនសិលាជាលាយលក្ខណ៍អក្សរ១ ។

ការធ្វើសង្គាយនាក្នុងរជ្ជកាលនៃព្រះបាទធម្មាសោករាជ បានធ្វើក្នុងរវាង ព.ស. ២៩៩[1] មានព្រះថេរៈជាការកសង្ឃចំនួន១០០០រូប ចាត់ជាតតិយសង្គាយនា ( សង្គាយនាគ្រាទី ៣ ) ក្នុងបណ្ដាសង្គាយនាក្នុងព្រះពុទ្ធសាសនា ហើយចាត់ថាជាគ្រាសំខាន់បំផុត ព្រោះទីប្រជុំបានមានមតិឲ្យបញ្ជូនព្រះថេរៈទាំងឡាយទៅប្រកាសព្រះពុទ្ធសាសនានៅនានាប្រទេស ក្នុងកិច្ចនេះ ព្រះបាទអសោកទ្រង់បានតាំងព្រះមហាមហិន្ទត្ថេរជាព្រះរាជបុត្ររបស់ព្រះអង្គឲ្យជាប្រធានក្នុងពួកព្រះថេរៈដែលត្រូវបញ្ជូនទៅប្រកាសព្រះពុទ្ធសាសនាក្នុងលង្កាទ្វីបគ្រាដំបូង ក្រៅពីនេះ ទ្រង់បញ្ជូនទៅប្រទេសដទៃៗទៀតជាច្រើន រួមជា ៩ គណៈព្រះថេរៈដែលត្រូវនិមន្តមកក្នុងដែនដីសុវណ្ណភូមិ គឺព្រះសោណឧត្តរត្ថេរជាប្រធាន ។

ម្យ៉ាងទៀត ដើម្បីជាតួយ៉ាងក្នុងការញ៉ាំងចិត្តនរជនទាំងឡាយឲ្យតែងមានសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនាឡើង ព្រះបាទធម្មាសោកទ្រង់បានលះរាជសម្បត្តិទ្រង់ព្រះផ្នួសក្នុងព្រះពុទ្ធសាសនាម្ដង ហើយទ្រង់ឲ្យចារឹកក្នុងផែនសិលា សំដែងគោលនៃព្រះពុទ្ធសាសនាជាច្រើន គោលសិលាចារឹកដែលទ្រង់ព្រះរាជបញ្ជាចាត់ឲ្យធ្វើក្នុងសម័យនោះ មានចំនួន ៨៤.០០០ ផែនឲ្យប្រតិស្ឋានក្នុងស្រុកតូច-ធំ ព្រមទាំងស្រុកដែលនៅក្នុងអំណាចចក្រពត្តិរបស់ព្រះអង្គ ដូចយ៉ាង អាហ្វ-ខានិស្ថាន, បេលូគិស្ថាន, កស្មីរៈ នេប៉ាលជាដើម ។ បណ្ដាសិលាចារឹកទាំងនោះ សព្វថ្ងៃគេបានរកឃើញជាង ៣០ ផែន បានពិនិត្យមើលឃើញអក្សរចារឹកក្នុងផែនសិលានោះមានសេចក្ដីផ្សេង ៗ គ្នា អ្នកប្រាជ្ញខ្លះបានឲ្យមតិថា គោលសិលាចារឹកទាំងនេះ មិនមែនមានតែត្រឹមសីលធម៌ប៉ុណ្ណោះទេ មានទាំងច្បាប់បញ្ញត្តខ្លះផង ព្រោះមានសេចក្ដីខ្លះ បញ្ញត្តដាក់ទោសដល់អ្នកប្រព្រឹត្តលើស ។

សេចក្ដីសំខាន់ក្នុងសិលាចារឹកនោះ មានរាយជាលំដាប់ដូចតទៅគឺ :

ទី១- ហាមមិនឲ្យនរជនណាមួយសម្លាប់សត្វធ្វើជាអាហារឬធ្វើពលិកម្មជាដាច់ខាត ។

(១)ច្បាប់សង្គីតិកថា ថារវាង ព.ស. ២៣៤ឆ្នាំ ។

ទី២–ឲ្យចាត់ផែនការរក្សាព្យាបាលមនុស្សនិងសត្វទាំងពួងដែលឈឺ ព្រមទាំងឲ្យដាំដើមឈើដកអណ្ដូងទុកក្បែរផ្លូវសម្រាប់ជនសញ្ចរទៅមក ។

ទី៣ -ឲ្យជនទាំងពួងប្រតិបត្តិតាមនាទីដែលគប្បីមានដល់គ្នាហើយ ផ្សាយគោលធម៌ដ៏ធំរបស់ព្រះពុទ្ធ-សាសនាផង ។

ទី ៤– ប្រៀបធៀបសភាពមុននិងសភាពសុខស្ងប់យ៉ាងត្រជាក់ចិត្តក្នុងរជ្ជកាលរបស់ព្រះអង្គ ។

ទី ៥– ចាត់ចែងបញ្ជូនសមណៈទូតចេញប្រ-កាសផ្សាយព្រះពុទ្ធសាសនានៅនានាប្រទេស ។

ទី៦ ចាត់តាំងភ្នាក់ងារឲ្យសំដែងប្រាប់និងត្រួតត្រាសីលធម៌របស់ប្រជាជន ។

ទី៧–សំដែងព្រះរាជហឫទ័យប្រាថ្នាក្នុងសភាពប្រក្រតីនៃសាសនា ហើយនិងភាពស្មើភាគក្នុងឋានៈរបស់មនុស្សទាំងឡាយ ។

ទី៨– ប្រៀបធៀបសេចក្ដីសម្រាន្តក្នុងលោកិយរបស់ក្សត្រសម័យមុន និងសេចក្ដីសន្ដោស, សេចក្ដីត្រេកអរក្នុងបុណ្យរបស់ព្រះអង្គ ។

ទី ៩– ប្រដៅជនទាំងឡាយឲ្យយកចិត្តទុកដាក់ក្នុងការស្វួង

(នៅមានត)

---

# ពិធីបុណ្យបញ្ចុះសីមា

(តពីលេខ ៩ មក)

បន្ទាប់ពីការសូត្រស្មូត្ររកថានោះមក មានចែកសៀវភៅនិក្ខាទកថានិងកថិនបរិយាយ ជាង ១០០០ ក្បាលដល់បព្វជិតនិងគ្រហស្ថដែលមករង់ចាំគគុញទទួលយកសៀវភៅជាធម្មទានដោយការជ្រះថ្លានៃក្រុមឧបាសក-ឧបាសិកា មានចៅកែតាន់-ហេង និងព្រះសមុហ៍គណ អ៊ុក-ឡេង ជាដើម ជាអ្នកកសាងសៀវភៅទាំងនេះ ទុកជាអំណោយក្នុងវេលាបញ្ចុះអដ្ឋិធាតុនោះ, វេលាយប់ម៉ោង ៨ និមន្តព្រះសង្ឃចំរើនព្រះបរិត្តរួចហើយ និមន្តព្រះរាជាគណៈ១ អង្គ សំដែងធម្មទេសនាតាមគម្ពីរបឋមសម្ពោធិកថាដំណាលកាលព្រះសម្ពុទ្ធចេញត្រាស់ជាដំបូងដោយសេចក្ដីគ្បោះក្បាយបរិយាយផ្សាយតាមឧគ្ឃោសនសព្ទចប់ហើយទើបសូត្រពុទ្ធាភិសេក ។

៣– ថ្ងៃសៅរ៍ ១៥កើត ខែ-ឆ្នាំ-ដដែល, ពេលព្រឹកម៉ោង ៧ និមន្តព្រះសង្ឃបង្សុកូល ហើយហែអដ្ឋិធាតុទៅបញ្ចុះក្នុងចេតិយដ៏តាមនិយមបវេណីពីបុរាណដែលបានធ្លាប់ធ្វើមកតែប៉ុណ្ណោះ, ពេលយប់ម៉ោង ៨ និមន្តធម្មកថិកពីររូបសំដែងធម្មទេសនាបុច្ឆាវិសជ្ជនាចប់ហើយ មានលេងរបាំមហោស្រពជាតិ ពួកក្រុមរាំក្មេងរបស់លោកវររេសនិយឯក ឈួនម្មុលពេជ្ររាំចាក់ចង្វាក់ក្បាច់ច្រៀងពន្យល់អំពីរឿងកសាងប្រទេសជាតិមាតុភូមិ ពួកជនប្រុសស្រីចាស់ក្មេង ច្រើនពាន់

គាត់ឈរណែនណាន់តាន់តាប់ពេញក្នុងទីវត្តទាំងមូល មើលមិនចេះអស់មិនចេះហើយសឹងដាច់ចិត្តប្រតិព័ទ្ធគ្រប់ៗគ្នាចំពោះរបាំនោះ តែគួរឲ្យមានសេចក្ដីទុក្ខវេទនានឹងមនុស្សជរាពិការ ផ្អើលមកមើលសប្បាយរីករាយជាមួយនឹងគេដែរ! ឱ!ហេតុតែកម្លាំងអានុភាពរបស់បុណ្យទាំងពីរនេះ ដែលពុទ្ធសាសនិកជនប្រកាន់កាន់អានជឿថាជាបុណ្យធំបណ្ដុលបណ្ដាច់ក្នុងព្រះពុទ្ធ-សាសនា បណ្ដាលនាំឲ្យមនុស្សជរាពិការទ្រមទ្រមចូលមកឃើញបុណ្យនេះផង បានមើលរបាំទាំងនេះផង គ្រាន់បានជាការបណ្ដោះនូវសេចក្ដីទុក្ខព្រួយរបស់ខ្លួនមួយពេលប៉ុណ្ណោះដែរ ។

៤–ថ្ងៃអាទិត្យ ១ កើត ខែ-ឆ្នាំដដែល ពេលព្រឹកម៉ោង ១០ រៀបចំព្រះសង្ឃដាក់ជាគណៈ-មហាថេរានុត្ថេរៈ-អនុគណ-ចៅអធិការ ទាំងពួកឧបាសកឧបាសិកា បណ្ដាលជនប្រុសស្រីទៀតជាច្រើនពាន់នាក់ មករង់ចាំទទួលសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយតាមមហាវិថីថ្នល់ជាតិរហូតដល់ទីបុស្សបុកមុខវិហារ, លុះសម្ដេចនិមន្តមកដល់ បានចុះអំពីរថយន្តហើយនិមន្តចូលទៅកាន់ទីបុស្សបុកដោយមានសំរ:គួរជាទីជ្រះថ្លា ព្រះសង្ឃបានសូត្រធម៌ "ជយន្តោ" ប្រគេនជាសព្ទសាធុការពរចំពោះសម្ដេចៗបានទទួលបដិសណ្ឋារៈដោយមានទឹកព្រះទ័យសោមនស្សជ្រះថ្លា ទើបមានថេរដីកាថា: "អាត្មាភាពមានសេចក្ដី អំណរចំពោះអស់លោក-អ្នកពុទ្ធបរិស័ទគ្រប់គ្នា សូមឲ្យបានប្រកបដោយសេចក្ដីសុខចំរើនតរៀងទៅ...." ហើយនិមន្តចូលទៅក្នុងវិហារថ្វាយបង្គំព្រះពុទ្ធរូបដោយសេចក្ដីគោរព ទើបនិមន្តចូលទៅកាន់ទីហោត្រ័យដែលគេបានរៀបចំគ្រឿងអាសនៈតាក់តែងបំរុងទុកប្រគេនជាអគ្គដ្ឋាន ។

លុះដល់ពេលរសៀលម៉ោង ៣ គេនិមន្តព្រះសង្ឃចំនួន ២០០ អង្គ មានសម្ដេចជាប្រធានចូលកាន់ទីវិហារសូត្រដកសីមាចាស់ហើយសូត្រចងសីមាថ្មីគ្រប់ទិសទាំង ៨ នាផ្ទៃផែនដីក្នុងវិហារនោះជាបដល់ហើយអស់កិច្ចបញ្ចុះសីមាត្រឹមតែប៉ុណ្ណេះ, បន្ទាប់ពីនេះ ទាយក-ទាយិកា បានយកតាឧបករណ៍ មានចីពរ-ស្បង់ជាដើម ប្រគេនព្រះសង្ឃទាំងនោះដែលមានឈ្មោះតាមកំណាន់ភោគរបស់ខ្លួនគ្រប់តែពេង ។

ដល់ពេលយប់ម៉ោង ៨ និមន្តសម្ដេចសំដែងធម្ម-ទេសនា ផ្សាយតាមឃោសនសព្ទ បំភ្លឺពន្យល់ពុទ្ធ-បរិស័ទអំពីដំណើររឿងបញ្ចុះសីមានិងបកិណ្ណកធម៌ដែលជាផលប្រយោជន៍នាំឲ្យយល់ស្គាល់ច្បាស់ក្នុងផ្លូវលោកនិងផ្លូវធម៌ អស់រយៈកាលពីរម៉ោងគត់ គួរជាទីញ៉ាំងចិត្តពុទ្ធបរិស័ទឲ្យជ្រះថ្លាចំពោះធម្មបរិយាយដោយសេចក្ដីក្រោះក្រាយនោះយ៉ាងក្រៃលែង ។

ឯករណីយកិច្ចទាំងពួង មានប្រគេនយាគូនិងភត្តាហារកំណត់តាមពេលដូចថ្ងៃទី ២ គ្រប់ទាំង ៤ ថ្ងៃ ថ្ងៃកតែថ្ងៃទី ២ មានចាក់ភាពយន្ត (កុន) ការម៉ើ-កាំងបញ្ចាំងរូបភាព ឲ្យពួកជនចាស់ក្មេងមើលជាទី

កំសាន្តចិត្តគួរឲ្យពិនិត្យរឿងរូបភាពនោះៗ ជាទីស្ងើចអស្ចារ្យ ឮសូរតែមាត់ស្រែកហៅហើយនឹងសើចទៅចល់គ្នានឹងម៉ោង ២ យប់ ទើបឈប់លែងលេង, នៅក្នុងទីកត្រើសមោសរ កំពុងភាពយន្ត(កុន)បញ្ចាំងរូបភាពជាប់នូវផ្ទាំងសំពត់សតែតៗញ័រៗ មានមនុស្ស ៤ នាក់ មានសរីរាយវៈស្លៀកពាក់ទុព្វលភាព អង្គុយក្បែរជ្រុងវិហារចាំសង្កេតមើលភាពយន្តនោះ ឮសូរលាន់មាត់ថា: "អ្ហក! ញាប់ញ័រៗ",

ប្រហែលជាមួយសន្ទុះស្រាប់តែមានកូនក្មេងម្នាក់ស្ទុះតេមកប៉ះចង្គុកចុងម្រាមដៃនៃមនុស្សទាំងនោះ ទឹងក្រញឹងឡើងថា "អាឯងក្រោញមកប៉ះយើងធើ!", ទើបខ្ញុំដឹងច្បាស់ថា ឱ! មនុស្សនេះ ពួកកួយអកទេតើ! ព្រោះឮសំដីនិយាយជាដំបូងហាមាត់ឡើងថាអក ពោលដូចជាសត្វអកដែលយំថាអក ៗ អ្ហក! ដូច្នោះដែរ, កួយនិយាយពាក្យថា "ញាប់ញ័រ" ឮសូរពាក្យស្រួយខ្យល់ (រ) ចេញមកច្បាស់ប៉ះ, ត្រង់ពាក្យថា "ក្រោញ" ប្រែថា រត់ ដែលខ្មែរយើងនៅអាយធ្លាប់និយាយថា "អានេះរត់ក្រោញបាត់ទៅហើយ" គឺរត់លឿនបាប់មិនទាន់ ។

នៅក្បែរបេងវត្តកំពង់ធំ មានគេចងគោក្របីដឹកប្រកផ្លូវ ខ្ញុំឮកួយស្រី ១ បែរមុខទៅរកគោក្របីស្ដីថា: "នរណា ចង អន្ទ្រូក់, អន្ទ្រាក នៅចំផ្លូវក្បែរប្រកនេះ" ខ្ញុំផ្ទៀងត្រចៀកបោលទៅឃើញកួយស្រី ១ ហៅគោថា អន្ទ្រូក់, ក្របីថា អន្ទ្រាក ខ្ញុំឆ្ងល់ណាស់ ខ្ញុំគិតដោយស្មានថា ប្រហែលជាកួយហៅយ៉ាងនេះ សំ-ដៅយកសណ្ឋានទ្រង់ទ្រាយដែលគោដើរប្ដូរបោលទៅបែបភាង "អន្ទ្រូក់ ៗ", ក្របីបែបភាងអន្ទ្រាក ៗ" ព្រោះដំណើរក្របីបែបភាងអឹកអៀក ៗ ដូច្នេះទេដឹង? ខ្ញុំតែងឮគេនិយាយថា កួយមាន ៣ ពួក គេហៅថា កួយអក, កួយពាំ, កួយអន្ទ្រូ តែត្រូវចាំស្ដាប់សំដីមើលសិនក្នុងពេលដែលពួកកួយទាំងនោះនិយាយគ្នាឡើង បើកួយណា លាន់មាត់និយាយជាដំបូង ១ ម៉ាត់ថា: អ្ហក អន្ទ្រូ ៗ យ៉ាងនេះ គប្បីកត់សំគាល់ថាកួយនោះគឺកួយអក, កួយអន្ទ្រូ ។ មនុស្សដែលនៅជាប់ដោយដោយព្រៃជាច្រើនទៀត គឺដែលគេហៅថា ស្ទៀង, រដែរ, សម្រែ, ចុំពួន, ក្រោល, កញ្ជ្រូក, ជ្រាយ, រអាង ។ល។ មនុស្សទាំងនេះ ច្រើនតែនៅត្រើយខាងមេគង្គខាងកើតនឹងខាងលិចឆ្ងាយពីទន្លេធំ ខ្ញុំគាន់តែនឹកឆ្ងល់ឡើងឆ្ងល់ឡើង អង្គុយសំកុកមិនដឹងជានឹងរកសួរមនុស្សណាឲ្យច្បាស់ការណ៍ តែគួរឲ្យសង្ស័យម្នាក់ឯងដោយសេចក្ដីបែងចិត្តគិតប្រមាណថា: ពួកមនុស្សទាំងនេះ ពីដើមប្រហែលជាជាតិពូជអម្បូរខ្មែរតែមួយ នៅរួមគ្នា ក្នុងស្រុកក្នុងភូមិរបរកេចចួលទានស្លៀកពាក់ ស៊ីចុកបុកចំពារដូចជាខ្មែរយើងដែរ ម៉េចហើយក៏បានជាក្លាយឈ្មោះទៅជា ស្ទៀង កួយ រដែរជាដើមយ៉ាងនេះ មានបើមកតែអំពីប្រកាន់ស្អិតនូវលទ្ធិណាមួយដែលជាកំណាន់ មិនព្រមរៀនសូត្រចុះចូលជឿស្ដាប់អ្នកណា រើផ្ទះសម្បែងថយចេញពីស្រុក,

ភូមិលែងនៅជាមួយនឹងអ្នកនោះបន្តិចម្តងៗ តែតទៅនៅក្នុងព្រៃភ្នំ និយមឈ្មោះហៅថាក្អួយជាដើមជាយូរយារណាស់មកហើយទេដឹង? បែកភាសានិយាយផ្សេងៗ ព្រោះគ្មានអក្សរសាស្ត្រផ្សាយទៅដល់ ម្ល៉ោះហើយពួកមនុស្សទាំងនេះ ខានបានចេះដឹងទាំងគ្មានទំនៀមទម្លាប់របស់អ្វីជាក់ស្តែងឲ្យជាសាក្សីពិតប្រាកដរហូតមកដល់សព្វថ្ងៃនេះ អំពើនេះគឺទៅមុខពួកមនុស្សទាំងនោះ បើមានពាសនាជោគជ័យ នឹងបានសិក្សាចេះដឹងឡើង គង់នឹងបានទៅជាមនុស្សមានសេរីថ្លៃថ្លាមិនខាន ។ ខ្ញុំបានប្រាប់តួនរឿងនេះឃ្លាតចាកករណីបុណ្យបន្តិច ព្រោះហេតុខ្ញុំមានសេចក្តីករុណាអាណិតព្រមទាំងប្រាថ្នាចង់ឲ្យមនុស្សទាំងនោះក្លាយទៅជាមនុស្សបានចេះវិជ្ជារួសរាន់ទាន់សម័យដូចសព្វថ្ងៃនេះផង ។

លុះព្រឹកថ្ងៃ ២ កេត ពួកបរិស័ទគ្រប់ភេទ បានរៀបយាគុភត្តាហារប្រគេនដល់ព្រះសង្ឃថែមទៀតជាភត្តទាន គំនាប់បុណ្យចេញពីវត្ត ទៅកាន់ទីលំនៅផ្ទះរបស់ខ្លួន, ដល់ពេលរសៀលម៉ោង ២ ជួបជុំព្រះសង្ឃនឹង ឧបាសក-ឧបាសិកា រៀបជូនដំណើរ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក និមន្តត្រឡប់មកភ្នំពេញវិញ សម្តេចបានចំរើនពរលាឡើងរថយន្តចេញផុតពីវត្តកំពង់ធំហើយ, ចំណែកព្រះសង្ឃគង់នៅវត្តឆ្ងាយៗក៏បានថ្វាយបង្គំលាគ្នាទាំងចំរើនពរលាឧបាសក-សិកាៗ ក៏បានថ្វាយបង្គំលាព្រះសង្ឃនឹងសំពះលាគ្នា យាត្រាទៅកាន់គេហដ្ឋានរបស់ខ្លួនវិញ ដោយមានទឹកមុខញញឹមជាសុខសួស្តីជ័យជោគគ្រប់ប្រការ ។

និពន្ធរឿងបុណ្យបញ្ចុះអដ្ឋិធាតុនឹងបុណ្យបញ្ចុះសីមា អស់តិចតួចការហោមពិធី ចប់ត្រឹមប៉ុណ្ណេះ ។

ព្រះពុទ្ធរង្ស្យ

ទេព - ស៊ុម

សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់

# ដំណើរចៅស្មែងទន្សាយទៅប្រទេសណេប៉ាល (ត)



ចៅស្មែងទន្សាយបានសួរទៅតាព្រាហ្មណ៍បាលថា: "លោកតាបានឃើញកិច្ចពីរបួ, ព្រះគ្រូ

វិមលបញ្ញា គង់-គូ នាមធាយាបិយសីលោ និងព្រះមហាអៀង-មន នាមធាយាមុនីជោតោ ដែលបាននិមន្តពីប្រទេសកម្ពុជា មករៀនប្រទេសលោបាល លោកតាបានជួបឬទេ? ។ លោកតាព្រិន្ទបាលតបថា: "តាមិនឃើញទេចៅ" ឃើញតែប្រាក់ចំនួន ៣.១៥៣ រូពី ដែលព្រះមហាថេរធម្មវរ: នៅអសោកាពម ញូវដែលហ៊ី(ប្រទេសឥណ្ឌា) បានផ្ញើមកជាមោទយសការសម្រាប់ការកសាងព្រះវិហារនៅលុម្ពិនី ។ ជាមោទយសការនេះ នៅទីក្រុងកណ្ឌមណ្ឌូ មានព្រះភិក្ខុ ចន្ទ្រមុនី មហាស្ថាវិរ ជាប្រធាន ។

ខ្ញុំបានដឹងច្បាស់ប្រាកដថា: ពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ និងសមាគមមិត្តសាលាបាលីបានរួបរួមគ្នាធ្វើបុណ្យផ្កានៅសាលាបាលីជាន់ខ្ពស់នាទីក្រុងភ្នំពេញជាលើកទី ១, កាលពីថ្ងៃទី ២២ ធ្នូ ១៩៥៣ ព្រមទាំងពួកពុទ្ធបរិស័ទទាំងបុរសស្ត្រីដែលបានចូលកុសលនិងសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ បានបច្ច័យទាំងអស់ ៣៨.៦៤៥រ,០០ ។ ក្នុងឱកាសពេលនោះ, ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូងទ្រង់បានព្រះរាជទានប្រាក់ ៥០០០រ,០០ ជាព្រះរាជអំណោយក្នុងមហាកុសលនេះផង ។ លំដាប់តមក មានលោកសូ-ពិនអតីតតំណាងរាស្ត្របានប្រមូលឧបាសកឧបាសិកាធ្វើបុណ្យផ្កាមួយទៀតនៅវត្តមង្គលវ៉ន, ក្រុងភ្នំពេញ (ប្រទេសកម្ពុជា) ជាលើកទីពីរ, ពីថ្ងៃទី ១ កក្កដា ១៩៥៣, ប្រមូលបានបច្ច័យចំនួន ៨.៣៥០ រៀល, សមាគមមិត្តសាលាបាលីបានចូលជាកុសលចំនួនប្រាក់ ២០០០រ,០០ រួមទាំងអស់ជាប្រាក់ ៤៨.៩៩៥រៀល ។

ប្រាក់នេះបានបែងជាពីរចំណែក:

១– ប្រាក់សម្រាប់សោហ៊ុយផ្សេងៗ ប្រគេនភិក្ខុ ២ អង្គ, ចំនួន ២៥.៤៩៥រៀល;

២– ប្រាក់សម្រាប់កសាងព្រះវិហារនៅលុម្ពិនី ២៣.៥០០រៀល ។

បើគិតជាប្រាក់រូពី គឺ: ប្រាក់ប្រទេសកម្ពុជា, ចំនួន ៧៤៨រ. ២៨ ប្តូរបាន ១០០ រូពី ។ គិតទៅប្រទេសកម្ពុជា បានចូលជាកុសលក្នុងការកសាងព្រះវិហារនៅលុម្ពិនី, ចំនួន ៣.១៥៣រូពី ។

ឯព្រះភិក្ខុពីររូបលោកគង់នៅឯអសោកាពម, ទីក្រុងញូវដែលហ៊ី (ប្រទេសឥណ្ឌា)ឯនោះមិនទាន់បានធ្វើដំណើរមកកាន់ទីក្រុងកត់មណ្ឌូនៅឡើយ ។

ឯតាព្រិន្ទបាលក៏តបមកវិញថា: "ល្អហើយៗ ចៅ!"

ចៅស្នេងទន្សាយ នៅសំណាក់ផ្ទះតាព្រិន្ទបាលមួយយប់ក៏វិលត្រឡប់មកតាមប្រទេសឥណ្ឌាមកដល់ទីក្រុងកល់កត្តា ។ នៅទីក្រុងនេះ ចៅស្នេងទន្សាយ បានជួបប្រទះនឹងអាពុកមាខាងមាតា ក៏ទៅសំណាក់នៅគេហដ្ឋាននោះ ។ ក្នុងពេលយប់នោះអាពុកមាមានអាពាធជាទម្ងន់ក៏ទទួលមរណភាពទៅ; អាពុកមា

នោះគ្មានបុត្រទេ ៗ ភរិយានឹងទៅស្នងទន្សាយជាក្មួយ ក៏បានបែងទ្រព្យសម្បត្តិចែកគ្នា ៗ ទៅស្នងទន្សាយ បានរៀបចំធ្វើបុណ្យឈាបនកិច្ចតាពុកមារួច ក៏ឡើងអាកាសយាន ទៅសហរដ្ឋអាមេរិក ៗ

(នៅមានត)

# រឿងតុក្កតាធ្វើពីទធិជាតិ

(តមក)



ការកាន់ទុក្ខនៃព្រះមហាក្សត្រ

ព្រះនាងទុក្ករាន៍ទ្រង់គង់នៅព្រះរាជដំណាក់ទ្រុងក្រោម ហើយទ្រង់ទតទៅទាំងមហាសាគរដោយមិនប៉ប្រិចព្រះនេត្រសោះ ព្រះចិន្តាព្រះនាងទ្រង់គិតទៅព្រះមហាក្សត្រ ....

នៅក្នុងព្រះរាជតំណាក់ប្រាំពីរជាន់ព្រះនាងសុខពន្ធ័ ដែលជាគាប់ព្រះរាជហឫទ័យនៃព្រះមហាក្សត្រ, ព្រះនាងកំពុងតែរុងរឿង ក្នុងទីប្រជុំនៃព្រះរាជបរិពារប្រាំរយនាក់ ទ្រង់មានព្រះទ័យសោមនស្សដោយគ្រឿងរតនៈវត្ថុគ្រប់យ៉ាង, ទ្រង់ក្រសាលដើម្បីគ្រងគ្រាប់ទូវសព្វបក្សីមាសយំអឺងកងក្នុងទ្រុងមាស ហើយផ្ទុំលើព្រះមញ្ចៈមាសរួចក៏សម្ងំលក់ទៅ... ៗ

* *
*

ចំណែកឯព្រះមហាក្សត្រ ទ្រង់គង់នៅលើស្ពានព្រះរាជនាវាមាស ( នាវាសុវណ្ណជ័យ ) មានបាំង មាសបាំងថ្វាយពីលើ, ទ្រង់ក្រេចទឹកនាជល់ព្រះអគ្គមហេសីច្បង, ព្រះនាងទុក្ខៈ តែងទ្រង់ទតយល់តែនិម្មិតរូប ព្រះភ័ក្ត្រក្រស្រស់ស្រោយនៃព្រះនាងសំណប់សុខពន្ធ័ប៉ុណ្ណោះ ទ្រង់មានព្រះបន្ទូលដោយព្រះអង្គឯងថា: " តើឥឡូវនេះព្រះនាងធ្វើអ្វី? ប្រហែលជានាងកំពុងគួតសក់ដែលមានព័ណ៌ដូចឈើខ្មៅ.... ៗ តើនាងធ្វើអ្វីទៀត? ប្រហែលនាងគូសគំនូរអ័លតា ( **Alta** ) នៅជុំវិញជើងនាងមានពណ៌ក្រហមដូចផ្កាកុលាប ... ឥឡូវនេះ នាងទៅបេះបុប្ផានៅឧទ្យានចាំងប្រាំពីរ ... នាងបានវិលត្រឡប់មកវិញដោយមានកាន់កន្ត្រកពេញទៅដោយបុប្ផា ដែលបេះពីសត្ត-ឧទ្យានប្រហែលនាងយកផ្កានោះ មកគ្រង .... នាងគិតមកអញ .... អើនាងគិតមកអញជានិរន្តរ៍ .... ភ្នែកនាងពេញទៅដោយទឹកភ្នែក... នាងលែងគ្រងផ្កា... ព្រួយចិត្តដែនាងធ្លាក់ល្អីទ្រុះអំបោះមាស ... កន្ត្រង



បុប្ផាត្រូវខ្យល់ទៅជិតជើងនាង ... ហើយពាល់ត្រូវនាង នៅដោយអាការបែបនេះ ... យំសោក ... ទឹកមក អញ ... ដេកមិនលក់ ... ។

ព្រះមហាក្សត្រទ្រង់ព្រះតំរិះបែបនេះឃើញនិមិត្តរូបព្រះនាងស៊ុយមូ ( សុខពនី )ដែលនាំឲ្យទ្រង់នឹកពេញព្រះរាជហឫទ័យឡើង បើតាមពិតព្រះនាងផ្ញើលក់ឥតបានទឹកនាដល់ព្រះមហាក្សត្រសោះឡើយ ... ។

ចំណែកព្រះរាជទេពីច្បង ដែលកំពុងពេញព្រះរាជហឫទ័យចំពោះព្រះមហាក្សត្រ ដោយផុតសង្ឃឹមព្រះនាងកំពុងសោយសោកនៅលើគន្ធរហែកហើយទតទៅខាងជើងមេឃនាទិសដែលព្រះរាជនាហ៍មាស (ព្រះរាជនាហ៍សុវណ្ណជ័យ) បាត់ស្រមោលបន្តិចម្តងៗ... ។ ព្រះមហាក្សត្រពុំមានចេតនាក្តុកដល់ព្រះនាងឡើយ ។

* * *

## នៅប្រទេសត្បូងទទឹម

ព្រះមហាក្សត្រទ្រង់ធ្វើព្រះរាជដំណើរអស់ដប់ពីរខែ, យាងទៅកាន់ភូមិភាគជិតហើយទឹងប្រទេសឆ្ងាយ ... ។ កន្លែងទី១ ជាលើកដំបូង, ទ្រង់យាងទៅដល់ប្រទេសត្បូងទទឹម ...

* * *

នៅប្រទេសត្បូងទទឹម, គ្រប់តែដំបន់សុទ្ធតែត្បូងទទឹម ... ជញ្ជាំងគេហដ្ឋានក៏ធ្វើពីត្បូងទទឹម ឃ័ត (Ghats) (១)សុទ្ធតែធ្វើទឹងត្បូងទទឹម, ផ្លូវទាំងអស់ក៏សុទ្ធតែក្រាលដោយត្បូងទទឹមដែរ ... ។

នៅប្រទេសដែលមានពន្លឺដ៏រុងរឿងនេះព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឲ្យគេធ្វើខ្សែដៃប្រាំបីគូដាំត្បូងទទឹមប្រាំបីពាន់គ្រាប់ដូចជាបុប្ផាក្រហមប្រាំបីពាន់រីកស្គុះស្គាយមានពណ៌ក្រហមដូចជាលោហិត ។

ព្រះមហាក្សត្រ ទ្រង់បានយកខ្សែដៃដែលដាំត្បូងទទឹមឡើងគង់លើព្រះរាជនាហ៍សុវណ្ណជ័យហើយយាងតម្រង់ទៅកាន់ប្រទេសមាសឬសុវណ្ណភូមិ ។

## នៅប្រទេសមាស

ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឲ្យពួកជាងទងនៅប្រទេសមាសយកមាសធ្វើ ឧបរៈជប់គូ ; កង់មាសទាំងនោះភ្លឺចាំងចែងដូចអណ្តាតភ្លើង; កង់មាសនោះ

១ ឃ័ត គឺជណ្តើរដែលចុះទៅក្នុងទន្លេពិសិដ្ឋហើយនៅលើនោះគេធ្វើសក្ការៈបូជា ។

ឮសូរសៀងពិរោះដូច វិណៈ(១) ហើយ ដល់ទន្តិចគ្នាឮរណ្តំពិរោះដូច មំទិរៈ(២) ។

ព្រមហាក្សត្រ ទ្រង់បានយកខ្សែដៃត្បូងទទឹមពីប្រទេសត្បូងទទឹម ហើយនិង នុបុរៈមាស ពីប្រទេសមាស ទ្រង់ឡើងគង់ព្រះរាជនាវាសុវណ្ណជ័យយាន តម្រង់ទៅកាន់ប្រទេសគជខ្យង ។

## នៅប្រទេសគជខ្យង

នៅប្រទេសគជខ្យង មានព្រះបរមរាជវាំង ដែលមានឧទ្យានផ្កាអស្ចារ្យនៅជុំវិញ ។ នៅក្នុងឧទ្យាននោះមាន កូនលលក (tourterelles) ពីរ; ជើងលលកធ្វើពីគជខ្យង ហើយចំពុះធ្វើពីត្បូងទទិម; លលកនោះទំនៅលើរុក្ខជាតិ មានស្លឹកកែវមរកត ។ លលកនោះចឹកជានិរន្តរ៍នូវចង្កោមគជខ្យង ; ពេលបុព្វណ្ហ-សម័យ, លលកនោះក្រាបពងគជខ្យងមួយ, ហើយដល់សាយណ្ហសម័យ, ព្រះអគ្គមហេសីនៅប្រទេសគជខ្យងទ្រង់យាងមករើសពងលលកនោះ ។

ព្រះអគ្គមហេសីទ្រង់បានយកខ្សែមកដោតក្រងជាកម្រង, ពេលយប់,យកមកដាក់ជិតព្រះកេសា; ដល់ថ្ងៃស្អែកពេលអរុណរះ ព្រះនាងទ្រង់យកកម្រងគជ-ខ្យងនេះចេញហើយបោះចោលទៅឆ្ងាយក្នុងឧទ្យាន ។

ក្នុងមួយរំពេច, ពួកទាសីនៃព្រះអគ្គមហេសីនាំគ្នារើសកម្រងគជខ្យងនោះ យកទៅផ្សារដូរនឹងនាវាមួយផ្ទុកប្រាក់ពេញ ។

ព្រះមហាក្សត្រ ទ្រង់បានទិញកម្រងគជខ្យងនេះសម្រាប់ព្រះនាង សុខពនី ហើយទ្រង់ព្រះរាជទាននូវនាវាផ្ទុកពេញទៅដោយប្រាក់ទៅលក់ ។

## នៅប្រទេសត្បូងកណ្តៀងខៀវ

ព្រះមហាក្សត្រទ្រង់បានយកខ្សែដៃត្បូងទទឹមពីប្រទេសត្បូងទទឹម នុបុរៈមាសពីប្រទេសមាស កម្រងគជខ្យងពីប្រទេសគជខ្យង ហើយទ្រង់យាងទៅដល់ប្រទេសត្បូងកណ្តៀងខៀវ ។

មហារាជនៅប្រទេសត្បូងកណ្តៀងខៀវទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គ ។ ព្រះរាជបុត្រីទ្រង់មានព្រះរាជឧទ្យានល្អសម្រាប់វស្សានរដូវ ។ នៅក្នុងព្រះរាជ-ឧទ្យាននោះ មានរុក្ខជាតិមួយដើម សន្ទឹកជាត្បូងកណ្តៀង; ដង្កូវនាងស្អិតនៅពាសពេញស្លឹកពណ៌ខៀវថ្លៃមេឃ; ដង្កូវនាងទាំងនេះបានធ្វើសំបុកក្លីប្រាលដូចគ្គា ស្រាលដូចរំយោ ហើយមានពណ៌ខៀវដូចមេឃ... ។

ពេលយប់ព្រះអង្គម្ចាស់ក្សត្រី ទ្រង់គង់លើរានហាលក្រោមត្បូងកណ្តៀងខៀវ, ទ្រង់យកសូត្រខៀវនិងខ្សែមាស,ត្បាញសំពត់សារីល្អអស្ចារ្យដូចជាមេឃដែលមានតារាក្លីពាសពេញក្នុងពេលរាត្រី ។ ព្រះនាងបានទុកជានិរន្តរ៍ទៅមេឃ ដើម្បីនឹងយកជាគំរូត្បាញសំពត់សារីនោះធ្វើតាមឲ្យដូចប្រាថ្នា ។

ត្រូវប្រើរយៈវេលា ប្រាំមួយខែទើបត្បាញសំពត់សារីប្រកបដោយតារាក្លីខៀវដូចមេឃ, ស្រាលដូចរំ

---

១ វិណា គ្រឿងប្រគំភ្លេង ។ ២ មំទិរៈគ្រឿងប្រគំភ្លេង ។

យោព្រាលផ្កាដូចគ្នានោះហើយ ។

ព្រះអង្គម្ចាស់ក្សត្រីទ្រង់គន់ព្រះពស្តុសារីរៈទៀត, ទ្រង់ស្តេចទៅកាន់ព្រះវិហារដើម្បីនឹងយកគ្រឿងសក្ការៈទៅបូជាព្រះធិលកន្ធៈជាអាទិទេពមានគទៀត(១) ។

ដល់ព្រះនាងទ្រង់យាងត្រឡប់ពីព្រះវិហារវិញ ទ្រង់ផ្លាស់យកព្រះពស្តុសារីរៈទៀតដូចជាមេឃ, ស្រាលដូចកយោ, ក៏ព្រាលផ្កាដូចគ្នាហើយទ្រង់ប្រទានទៅពួកពាសីយកទៅដូរឯផ្សារ នឹងនាក់ប្រាំពីរផ្លុកសុទ្ធតែមាស ។

ព្រោះហេតុដូចនេះបានជាព្រះមហាក្សត្រទ្រង់បានព្រះពស្តុសារីដែលទ្រង់មានព្រះរាជបំណង នឹងយកទៅឲ្យព្រះនាងសុខពទី ដែលជាទីពេញព្រះទ័យរបស់ព្រះអង្គ ។

(មានត)

---

## រឿងជ័យប្រាជ្ញ (ត)

ព្រឹកឡើងព្រះមហាក្សត្រាត្រាស់បង្គាប់ឲ្យកុមារជ័យ មួយអន្ទើដោយពួកសេវកាមាត្យយកសេះឲ្យគ្រប់គ្នាមកដើម្បីនឹងហែព្រះអង្គទៅក្រសាលព្រៃ បើអ្នកណាគ្មានសេះត្រូវមានទោស ។ ពួកសេវកាមាត្យព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីគេណ្ឌយកសេះបានមកគ្រប់គ្នាហើយតាមហែព្រះអង្គទៅ ។ ចំណែកកុមារជ័យដើររកសេះមិនបានសោះ ព្រោះសេះពួកអាមាត្យទាំងឡាយគេណ្ឌយកអស់គ្មានសល់ ។

ពួកសេវកាមាត្យនឹងនាម៉ឺនសព្វមុខមន្ត្រីបានហែព្រះមហាក្សត្រចេញទៅហើយ ចំណែកកុមារជ័យពាល់ប្រកពុំដឹងគិតដូចម្តេច ក៏យកធាងចេកមកលាក់ជាក្បាច់ធ្វើក្បាលសេះនឹងសេះចត្រង្គ ១ មកកាន់នឹងដៃរួចចំប្រឹងរត់តាមហែព្រះមហាក្សត្រយ៉ាងអស់ទំហឹង លុះត្រាតែទាន់ កាលបើទាន់ហើយក៏ដាក់សេះធាងចេកនោះខាងក្រោមក្លៀក ដៃម្ខាងកាន់សេះចត្រង្គហុចទៅមុខ ដៃម្ខាងចប់សេះធាងចេកនោះរត់តាមប្រកិតពីក្រោយគេបង្អស់ ។

លុះដល់ទីក្រសាលហើយ ព្រះមហាក្សត្រមិនឃើញកុមារជ័យមានសេះនឹងគេ ក៏ទ្រង់ត្រាស់សួរថា នែអាជ័យ ! ដូចម្តេចមិនឃើញមានសេះនឹងគេ ?

កុមារជ័យ– សូមទ្រង់ព្រះមេត្តាប្រោស, សេះទូលព្រះបង្គំមានដល់ទៅពីរ គឺសេះ១សម្រាប់រត់យោងមុខសេះ១សម្រាប់ជិះ ។

ព្រះមហាក្សត្រ–ឯណាសេះសម្រាប់ជិះ, ឯណាសេះសម្រាប់រត់យោងមុខ ?

កុមារជ័យ– លើកសេះធាងចេកឡើងថ្វាយឲ្យទ្រង់ទត ថានេះសេះសម្រាប់ជិះ, លើកសេះចត្រង្គឡើងថ្វាយឲ្យទ្រង់ទត ថានេះសេះសម្រាប់រត់យោងមុខ ។

---

(១) ព្រះស្តូវៈ ដែលមានគកទៀតក្រោយដែលព្រះអង្គបានឈោប ខសចិត្តលនៃពិភពលោក ។

ព្រះមហាក្សត្រ បញ្ចេញអាការហាក់ដូចជាខ្ញាល់ហើយមានបន្ទូលថា ម្ដេចក៏អាឯងយកសេះនេះមក? ឯងឃើញទេគេពល់គ្នាគ្មាននរណាមួយគេយកសេះដូចជាសេះអាឯងនេះទេ?

កុមារជ័យ—. សូមទ្រង់ព្រះមេត្តាប្រោស ព្រឹកមិញនេះ ព្រះករុណាថ្លៃវិសេសទ្រង់មានបន្ទូលឲ្យយក "សេះ" ។ ពាក្យថា "សេះ" ជាពាក្យមិនទាន់ប្រាកដនៅឡើយ ព្រោះគ្មានស័ព្ទបញ្ជាក់បន្ថែមលើពាក្យថា "សេះ" នោះទៀត, ឲ្យច្បាស់ថា "សេះរបៀបនេះ, សេះរបៀបនោះ" សោះ ។ ហេតុដូចនេះបានជាខ្ញុំព្រះបង្គំយល់ថាទឹងយកសេះបែបណាមកក៏បានគ្មានទាស់; ព្រោះសេះឈាន់ចេកទឹងសេះបត្តិក៏គេហៅថា "សេះ" ដែរ ; សេះមានជីវិតអាចរត់ខ្លួនឯងបាន ក៏ហៅថា "សេះ" ដែរ ។ បើធម្មជាតិទាំងពីរបែបនេះគេហៅថា "សេះ" ដូចគ្នាទឹងថាសេះរបស់ខ្ញុំព្រះបង្គំមិនមែនសេះទៅវិញដូចម្ដេចកើត ។ សូមទ្រង់ជ្រាប ។

ព្រះមហាក្សត្រ- បើយ៉ាង់នេះឯងយល់ថាអញខុសឬ?

កុមារជ័យ – សូមទ្រង់ព្រះមេត្តាប្រោស ព្រះមហាក្សត្រក៏គ្មានខុសខ្ញុំព្រះបង្គំក៏គ្មានខុស ព្រោះទ្រង់ត្រាស់បង្គាប់ឲ្យខ្ញុំព្រះបង្គំយកសេះ ខ្ញុំព្រះបង្គំក៏យកសេះតាមព្រះរាជបម្រាស់មែន ; បើអ្នកណាថាខ្ញុំព្រះបង្គំខុស អ្នកនោះឈ្មោះថាថ្វាយកំហុសទៅលើព្រះករុណាថ្លៃវិសេសដែរ ព្រោះខ្ញុំព្រះបង្គំមិនមែនធ្វើដោយចិត្តឯងទេ ។

ព្រះមហាក្សត្រទ្រង់ទទួលពាក្យដោះស្រាយរបស់កុមារជ័យដោយតុណ្ហីភាព ។

លុះទ្រង់ត្រឡប់មកដល់ព្រះបរមរាជវាំងវិញ ; ក្នុងថ្ងៃមួយនោះ ទ្រង់ត្រាស់បង្គាប់ឲ្យកុមារជ័យទៅបោសក្រោមព្រះរាជដំណាក់, គ្រានោះពួកអស់អ្នកបានឃើញកុមារជ័យ កំពុងតែបោសនៅខាងក្រោមក៏នាំគ្នាដើរទន្រ្ទាំពីខាងលើ គ្រាំចុះគ្រាំឡើង កុមារជ័យនឹកក្នុងចិត្តថា ឱ! អ្នកអស់ទាំងនេះ ដើរទន្រ្ទាំលើក្បាលអញ ដោយចិត្តមើលងាយទេតើ! បើដូច្នោះអញមិនត្រូវអត់ឲ្យទេ; គាល់បើពិចារណាសេចក្ដីក៏ច្បាស់ក្នុងចិត្តហើយ កុមារជ័យក៏ស្រែកជេរឡើងភ្លាមទៅ "យ៉ុះ! មេពោះដកទងចង្រៃអស់នេះ ខូចអី!ក៏ខូចម្ល៉េះ!រកស៊ីតែនឹងគូថ!បានស៊ីក៏មកតែពីគូថ! មិនបានស៊ីក៏មកតែពីគូថ! ម្ដេចក៏ហ៊ានឯងមិនស្គាល់ក្បាលអញ ។

ពួកអស់អ្នកទាំងនោះឮកុមារជ័យជេរដូច្នោះតូចចិត្តជាខ្លាំងណាស់ ទើបនាំសេចក្ដីនោះទៅក្រាបទូលព្រះមហាក្សត្រថា : បពិត្រព្រះករុណាថ្លៃវិសេស ! អាជ័យវាជេរខ្ញុំព្រះបង្គំថា ខ្ញុំទាំងអស់គ្នាអាក្រក់ណាស់ នាំឲ្យខូចកិត្តិយសដល់ព្រះអង្គផង ។ សូមកុំឲ្យវាទៅបោសទៀត ។

ព្រះមហាក្សត្រទ្រង់ត្រាស់សួរទៅវិញថា : ចុះ



វាជេរដូចម្ដេចខ្លះ? ចូរឯងប្រាប់អញមកមើល ?

ពួកអស់អ្នកក៏ក្រាបបង្គំទូលតាមពាក្យដែលកុមារជ័យជេរនោះដោយសព្វគ្រប់ ។

ព្រះមហាក្សត្រ· កាលបើទ្រង់ជ្រាបហើយទ្រង់ទឹកអាក់អន់ក្នុងព្រះរាជហឫទ័យយ៉ាងខ្លាំង បម្រុងនឹងយកទោសកុមារជ័យ ដោយព្រះដម្រិះថា: "ឯងស្រឡាញ់វាជាងគេទាំងអស់ ឥឡូវនេះវាហ៊ានជេរអស់អ្នកដទៃឯទៀតគឺវានេះបញ្ឈឺចិត្តឯងយ៉ាងពេញទំហឹងឲ្យឯងខ្មាសគេដោយសារវា; ប៉ុន្តែបើនឹងយកទោសវាតែម្ដងទៅ ឃើញថាមិនសមហេតុ·ផល ចាំហៅវាមកសាកសួរឲ្យដឹងដើមទងសិន" ទើបទ្រង់ត្រាស់ប្រើអាមាត្យឲ្យទៅហៅកុមារជ័យមក ។

កុមារជ័យមកដល់ហើយក៏ក្រាបថ្វាយបង្គំអង្គុយក្នុងទីដ៏គួរ ។

ព្រះរាជាត្រាស់សួរថា "នែអាជ័យហេតុអ្វីក៏អាឯងជេរអស់អ្នកយ៉ាងនេះ អញរាប់អានស្រឡាញ់ឯងអាឯងរឹតតែបានចិត្តឡើង ជេរព្រហើនហ៊ានដទៃមករកអញទៀត អ៊ីចឹងមែនឬ ?

(មានត)

---

# ប្រវត្តិក្មេងកំព្រា

តពីលេខ ៩ មក

ហើយនឹងធន-សារឿន? សំណាង-អ្នកនាងមានការដូចម្ដេចសូមមានប្រសាសន៍មក-បងមានបានទិញវត្ថុផ្ញើជូនពុកនឹងប្អូនស្រីបងទេ – ខ្ញុំពុំបានទិញវត្ថុផ្ញើជូនពុកនឹងប្អូនស្រីខ្ញុំឡើយ ដោយខ្ញុំសំចៃប្រាក់បន្តិចបន្តួចទុកប្រើប្រាស់ក្នុងពេលដែលខ្ញុំត្រូវត្រឡប់ទៅលេងស្រុកកំណើតវិញ· ប៉េហ្វឹង! បងយករបស់អស់នេះទៅ·ដៃនាង៖ញយកកូនបន្ទប់តូចមួយ ដាក់នោះលើតុ: សំណាង; ខ្ញុំលាបងសិនហើយកុំឲ្យបងចង្អៀតចិត្តព្រោះតែខ្ញុំអង្គុយនៅបន្ទប់បងនេះៗមាត់ក៏និយាយ ជើងក៏ដើរទាំងថយផុតពីបន្ទប់ ទុកសំណាងឲ្យអង្គុយនៅតែម្នាក់ឯង ដែលកំពុងមានអាការស្រមើស្រមៃវិស័យមនុស្សយល់សប្តិ ៗ សំណាងអង្គុយប្រឹងមួយស្របក់ ដូចជានឹកឆ្ងល់; តមកគេឃើញសំណាងចាប់យកកញ្ចប់តូចនោះមកលាដោយថ្នម ៗ នៅក្នុងកញ្ចប់មានគន្ធពិដោរគ្រប់បែបនឹងលិខិតពីរសន្លឹកមួយមានស្រោមបិទមួយទៀតលាត ៗ

សេចក្ដីក្នុងលិខិតលាត

ឲ្យបងយកទឹកអប់ពិដោរ ប្រេងលាបសំអាតសក់ពីរដបនឹងម្សៅពីរប្រអប់ប្រគល់ដៃប្អូនស្រីបងទុកជាបញ្ញើ

ដែលបងទិញដោយដៃឯងលិខិតតូចមួយទៀតសូមជូនបងដោយផ្ទាល់ដៃ – បើបងចង់ដឹងសូមបើកមើលចុះ

ហត្ថលេខា

ជន-សារឿន

## លិខិតទីពីរ

ស្រោមលិខិតក៏របើកចេញនៅក្នុងស្រោមគេឃើញមានក្រដាសប្រាក់ ១០០ រៀល ១៥ សន្លឹក នឹងមានរូបថតមួយផង មានលិខិតមួយជាប់នឹងរូបថតនោះសេចក្តីដូចតទៅ –

សំណាងបង! មុននឹងបងអានសំបុត្រនេះ ខ្ញុំសូមឲ្យបងកាន់ចិត្តឲ្យនឹង ចំពោះករណីយដែលខ្ញុំជំរាបមកបង ចំណែកបងក៏ពុំអាចជ្រាបបានថា ខ្ញុំជាស្រីមានឋានៈ បែបណាមួយឡើយ រវាងជាបីឆ្នាំមកហើយ បងនឹងខ្ញុំ ក៏ពុំដែលមានសំដែងសេចក្តីស្មោះស្ម័គ្រ ចំពោះស្ថានការណ៍ណាមួយដែរ គ្រាន់តែជួបមុខគ្នា ហើយពោលពាក្យទៅមករកគ្នាតាមធម្មតាប៉ុណ្ណោះ ; ពេលនេះខ្ញុំសូមហែកបង្ហាញ នូវទឹកចិត្តដ៏ស្មោះរបស់ខ្ញុំ ជូនបងទុកជាសណ្ដាប់ នេះជាករណីយមួយដែលខ្ញុំត្រូវលះកាត់សេចក្តីអៀនខ្មាស ។

ខ្ញុំសូមជូនប្រាក់ ១០០០ រៀល ទុកគ្រាន់ឲ្យបងចាយវាយក្នុងវិស្សមកាលនេះ ៥០០ រៀល ឲ្យបងជាវវត្ថុអ្វីមួយដ៏គួរផ្ញើជូនឪពុកបង នឹងរូបថតរបស់ខ្ញុំមួយសន្លឹកទុកឲ្យបងដាក់ជាប់នឹងខ្លួនជាអនុស្សាវរីយ៍ រូបនេះសូមបងរក្សាឲ្យគង់កុំបណ្ដោយឲ្យវិនាស ដោយហេតុណាមួយ បើបងចង់ជ្រាបច្បាស់នូវទឹកចិត្តរបស់ខ្ញុំ សូមបងយកតែរូបខ្ញុំមកមើល ហើយពិនិត្យឲ្យយូរទៅ គង់បងជ្រាបបានដោយប្រាកដ ។

ហត្ថលេខា

ជន-សារឿន

កាលបើអានលិខិតចប់ហើយ សំណាងក៏គិតគំនិតមួយចំក្សមថា: ឱ! កាមគុណពេលនេះអ្នកមកសណ្ឋិតចិត្តខ្ញុំហើយអ្នកធ្វើឲ្យខ្ញុំលិចលង់ព្រោះតែសេចក្តីស្នេហាឬ? ជន-សារឿន ពុំបានដឹងច្បាស់នូវប្រវត្តិរបស់អាត្មាអញឡើយ នាងទើកស្មានថា អាត្មាអញ ជាបុគ្គលកើតនៃលោកដ៏ឆ្នៅប្រសើរ បានជានាងពោលយ៉ាងនេះ ហើយបើសិនជាអាត្មាអញ បង្ហាញសេចក្តីពិត ដល់នាងទៅប្រហែលជានាងអាចដកថយនូវសេចក្តីស្នេហាខ្ញុះមិនខានតែរូបអាត្មាអញគង់នៅជាប់សេចក្តីស្នេហាលើនាងវិញ ; បើពោលទៅតាមឋានៈនៃពូជពង្សអាត្មាអញ មិនគួរទទួលយកនាងជាភរិយាបានទេ ; បើពោលទៅតាមឋានៈនៃវិជ្ជាប្រហែលជាគួរដល់ការគ្រប់គ្រងនាងដែរ នេះហៅសែនលំបាកចិត្តមែន សេចក្តីស្នេហា? ពត្រីមួយចាំងមូលមិនអាចធ្វើសំណាងចុះកាន់និទ្រាបានឡើយ អ្នកសម្ងំក្នុងបន្ទប់ដោយអាការបែបនេះ លុះត្រាតែព្រះអាទិត្យបញ្ចេញពន្លឺដាស់ប្រជាជនគ្រប់គេហស្ថានរៀងខ្លួន ។

រាត្រីកន្លងផុត ; សំណាង ក៏ចាប់ធ្វើដំណើរ ក្រោយពេលដែលបានលាលោកឧកញ៉ាធនសារី នឹងនារីដែលធ្វើឲ្យអ្នករំជួលចិត្តអស់រាត្រីមួយ ។ ក្នុងដំណើរនេះគេបានពាំជាប់នូវសេចក្ដីរីករាយលាយនឹងសេចក្ដីវិតក្កដែលធ្វើឲ្យអ្នកចេះតែលួចញញឹមនឹងស្រពោនតែម្នាក់ឯង; គួរឲ្យចាប់ចារម្មណាស់ បើសិនជាជនណាមួយបានពិនិត្យអាការរបស់សំណាង ។

ម៉ោង១២,១៥ គេឃើញលោកដស្នើប្រសើរនឹងបុត្រីលោកឈររង់ចាំនៅចំណតរថយន្តក្នុងទីរួមខេត្ត ; សំណាងចុះពីរថយន្តដោយសេចក្ដីត្រេកអរជាអនេក ព្រោះតែបានជួបឪពុកចិញ្ចឹមនឹងប្អូនស្រីអ្នកមកចាំទទួលដំណើរ ក្នុងការវិលត្រឡប់របស់សំណាងនឹងគ្រួសារលោកដស្នើក៏គ្មានសេចក្ដីប្លែកប៉ុន្មានដែរ ។

ពីរថ្ងៃក្រោយមកអ្នកឈ្លៀតឱកាសទៅកាន់សំណាក់លោកគ្រូចៅអធិការវត្តព្រៃតុម្ព ដើម្បីបំពេញការកិច្ច ។

ថ្ងៃ ១៥ កើតខែជេស្ឋ,សំណាងត្រូវធ្វើដំណើរទៅកាន់ផ្នូរឪពុករបស់អ្នកដើម្បីបំពេញកិច្ចបោសសំអាតនឹងបោចស្មៅនៅជុំវិញផ្នូរចេញ ព្រមទាំងបេះផ្កាឈើមកបូជាកន្លែងសពឪពុកអ្នក; ពេលនោះ គួរឲ្យអាសូរដល់រូបសំណាងយ៉ាងអនេក បើសិនជាយើងបានឃើញករណីយរបស់សំណាង; អ្នកលុតជង្គង់ផ្គងអញ្ជលីទៅកាន់ផ្នូរ ដែលមានទឹកភ្នែកហូររហាមកាត់មុខ; នេះហើយជាលើកដំបូងដែលអ្នកត្រូវបង្ហូរទឹកភ្នែកនៅទីចំពោះមុខផ្នូរ ។ អ្នកបានធ្វើសេចក្ដីបួងសួងដែលលាយឡំដោយអាការអាក់អួលចំពោះមុខផ្នូរឪពុកអ្នកដោយសេចក្ដីយ៉ាងខ្លីដូចតទៅ: បពិត្រលោកដ៏មានគុណ កូនពុំបានចំណាំមុខលោកច្បាស់ថាមានទ្រង់ទ្រាយបែបណាទេ តែកូនចាំច្បាស់ថាលោកបានលះបង់ជីវិតពេលកូននៅទីនេះ ព្រោះតែការបៀតបៀនរបស់ជនទុច្ចរិត កូនចាំមិនភ្លេចទេចំពោះជនអ្នកផ្ដន្ទានឹងអ្នកសង្គ្រោះដល់រូបកូន សូមលោកឲ្យពរដល់លោកតាសំ, លោកគ្រូចៅអធិការ, លោកដស្នើប្រសើរ នឹងលោកឧកញ៉ាធនសារីមួយអន្លើដោយ....., ដល់ត្រង់នេះនាំឲ្យសំណាងចុកណែនក្នុងទ្រូងស្ទើរតែបាននិយាយទៅទៀតពុំរួចព្រោះសេចក្ដីវេទនាដែលមិនគួរយកមកដំណាលបាន, ទើបអ្នកបន្ថែមថា បុត្រីលោក ។ ខ្ញុំសូមតាំងទីនេះជាបូជនីយដ្ឋានរបស់ខ្ញុំចាប់តាំងពីសម័យនេះតទៅ .... ។

បន្ទាប់ពីនោះ សំណាងបានថយចេញពីផ្នូរ ដោយសេចក្ដីក្រៀមក្រំយ៉ាងខ្លាំងហើយធ្វើដំណើរទៅសំណាក់នៅគេហស្ថានតាសំ ដែលអ្នកស្រឡាញ់ទុកដូចជាឪពុករបស់អ្នកដែរ, តាសំស្រឡាញ់សំណាងទុកដូចជាកូនតែមានការកោតខ្លាចសំណាងយ៉ាងច្រើនព្រោះឃើញអ្នកមានកិរិយាថ្លៃថ្នូរនឹងចំណេះវិជ្ជាគួរជាទីស្រឡាញ់នឹងកោតខ្លាច ។ ក្នុងរាត្រីនោះសំណាងនិទ្រាពុំលក់ទេ ចេះតែរសាប់រសល់ក្នុងខ្លួន ដូចជាប្រផ្នូលនឹងមានព្រឹត្តិការណ៍កើតឡើង សំណាងអផ្សុក

ណាស់ក៏ចេញមកឈរនៅក្បែររបងជិតផ្ទះក្រោមពន្លឺព្រះចន្ទយ៉ាងភ្លឺច្បាស់, កត្រែដ៏សំខាន់នេះព្រះចន្ទបានបញ្ចេញពន្លឺយ៉ាងអស្ចារ្យ អាចធ្វើឲ្យសំណាងយកសៀវភៅប្រវត្តិសាស្ត្រលោកមកអានបានដោយងាយ ។

ក្នុងពេលដែលអ្នកកំពុងអានសៀវភៅ ដើម្បីបំបាត់សេចក្តីតក្ក អ្នកបានបោលភ្នែកមើលចំពៅខាងមុខ ស្រាប់តែប្រទះ ស្រមោលមនុស្សម្នាក់ស្លៀកសពាក់សជិះសេះស អណ្តែតតាមអាកាស ចូលមករកអ្នកបន្តិចម្តង ៗ ធ្វើឲ្យអ្នកឈរសំឡឹងដោយការភាន់



ភាំងហាក់ដូចជាក្លែងស្មារតី អ្នកបានដំរង់ស្មារតីមើលបញ្ជាក់ទៅកាន់រូបនោះទៀត ក៏នៅតែឃើញដូចដែល ហើយកាន់តែអណ្តែតមករកខ្លួនអ្នក ។

នៅចម្ងាយជាប្រាំម៉ែត្រទឹងដល់រូបអ្នកស្រមោលនោះក៏ឈប់ទឹង; សំណាងចំពិនិត្យឲ្យជាក់តែនៅមិនប្រាកដ ទឹងស្លរក៏ហាក់ដូចជាហាមាត់និយាយមិនបាន នាំឲ្យអ្នករំខានចិត្តជាខ្លាំង; ពេលដែលអ្នកកំពុងភ័យញ័រមិនដាច់ ស្រាប់តែឮសំឡេងមនុស្សនិយាយចេញពីស្រមោលនោះមកថា នែ! សំណាង កូន! កុំខ្លាចអ្វី ឪពុកអាណិតកូនឯងណាស់ សព្វថ្ងៃឪពុកនៅថែរក្សាក្នុងនគរនេះ ឪពុកគ្មានសេចក្តីលំបាកអ្វីទេ ចូរឯងឈប់យំសោកនឹងឪពុកទៅ ហើយព្រឹកស្អែកនេះ ឯងបបួលតាសំពៅគាស់ផ្នូរឪពុក ។ កាលបើផល់ហើយ ចូរឯងគាស់យកឆ្អឹងឪពុកឡើង តែមុននឹងលើកឆ្អឹងចេញពីផ្នូរ ត្រូវឯងពិនិត្យមើលត្រង់ឆ្អឹងក្បាលជាមុនសិន នោះនឹងឃើញប្រអប់ស្ពាន់តូចមួយ ហើយប្រញាប់យកប្រអប់ដាក់ហោប៉ៅភ្លាម សឹមរើយកឆ្អឹងឪពុកជាខាងក្រោយ ៗ លុះត្រឡប់មកដល់ផ្ទះត្រូវឯងយកប្រអប់នោះបើកមើលក្នុងទីស្ងាត់ឯងនឹងឃើញវត្ថុមួយដែលមានដំឡៃយ៉ាងច្រើនហើយឯងមានសិទ្ធិត្រូវប្រើវត្ថុនោះ តែប្រយ័ត្នរក្សាកុំឲ្យឃ្លាតចេញពីខ្លួនព្រោះវត្ថុសក្តិសិទ្ធិនេះនឹងជួយឯងបានក្នុងពេលដែលឯងមានហេតុ តែត្រូវនមស្សការព្រះរតនៈត្រ័យហើយនឹកដល់អញសិន, ទីបំផុតឪពុកផ្តាំឯងថាកុំឲ្យជឿពាក្យគេមុនពិចារណា, ចំណែកឆ្អឹងអញត្រូវយកទៅដុតយកសំណល់ទៅដំកល់ទុកនាវត្តអំពិលបឹស្សីកែវចុះ ... ។

សំឡេងដែលឮពីរូបស្រមោលក៏បាត់ភ្លាមជាមួយរូបក្នុងខណៈដែលនិយាយចប់ធ្វើឲ្យសំណាងរឹតតែជឿងឆ្ងល់យ៉ាងខ្លាំងនឹងរកជនណាមួយជួយពិចារណាផងពុំ

បាន ។

ក្រោយនោះបន្តិច សំណាងក៏ឡើងទៅកាន់ដំណេកវិញជាមួយនឹងសេចក្តីសង្ស័យមិនចេះអស់ហើយ; អ្នកបានប្រាសខ្លួនទៅលើកន្ទេលក្រហមដែលក្រាលផ្ទាល់នឹងក្តារ យកដៃគងថ្ងាសពិចារណាចំពោះហេតុដែលទើបនឹងមានមកក្នុងពេលថ្មីៗនេះ បណ្តាលឲ្យអ្នកមានទឹកចិត្តអណ្តែតអណ្តូង ទៅកាន់អារម្មណ៍ដទៃជាច្រើន បណ្តោយទឹកចិត្តឲ្យដើរពាសពេញពិភពលោក អ្នកនិទ្រាមិនបានទេក្នុងរាត្រីនោះ គេចាត់ទុកជារាត្រីទីពីរក្រោយពីរាត្រីដែលអ្នក រៀបដំណើរចេញពីភ្នំពេញមក ។

ព្រឹកឡើងគេឃើញសំណាងនឹងតាសំលឹបមួយម្នាក់ចេញដំណើរទៅកាន់ព្រៃស្មសាន កាលបើដល់ហើយអ្នកទាំងពីរ ក៏ចាប់ធ្វើការតាមដែលបានគិតទុកមកតាមបណ្តាំក្នុងពេលរាត្រី ខំពិនិត្យតាមហេតុដែលបានដឹង មិនយូរប៉ុន្មានប្រអប់ស្លាន់តូចក៏ប្រាកដឡើង អ្នកបានយកដៃចាប់រើសដាក់ក្នុងហោប៉ៅដោយស្រួល ដល់ត្រង់នេះសំណាងត្រូវសំរកទឹកភ្នែកម្តងទៀត តែអ្នកខំទប់សេចក្តីសោកកុំឲ្យកើតឡើងបាន ។ ៣ ថ្ងៃក្រោយមក នៅផ្ទះតាសំមានធ្វើបុណ្យទក្ខិណានុប្បទានយ៉ាងឧឡារិក ហើយបានចាត់ចែងបូជាអដ្ឋិស្រស់ទៅជាអដ្ឋិធាតុ ; នៅទីបញ្ចប់ពិធីបុណ្យ គេយកធាតុទៅដាក់លំនៅវត្តអំពិលបី ឬស្សីកែវ ក្នុងឃុំកូនសត្វស្រុកកំពត (កំពត) ។ (នៅមានត)

# ប្រវត្តិខេត្តបាត់ដំបង

មុននឹងខ្ញុំបាទបរិយាយអំពីប្រវត្តិនៃខេត្តមួយៗ ក្នុងព្រះរាជាណាចក្រកម្ពុជរដ្ឋ សូមអភ័យពីសំណាក់លោកអ្នកប្រាជ្ញប្រវត្តិសាស្ត្រជាមុនសិន ក្រែងការស្រាវជ្រាវរបស់ខ្ញុំបាទពុំពិតប្រាកដ ដូចជារបស់លោក ដែលបានរកហេតុផលឃើញពីមុនមក បើសិនជាការនេះ នៅមានក្លាំងក្លាត់ច្រើនក៏សូមបណ្ឌិតប្រវត្តិសាស្ត្រទាំងឡាយ ជួយកែតម្រូវតាមគប្បីណាមួយ ដើម្បីឲ្យអាណាខេត្តប្រវត្តិរបស់យើងមានគោលដ៏ពិតប្រាកដឡើងៗ ព្រោះជាហេតុអ្វីមួយដែលយើងបានដឹងហើយ បន្ទុកតែក្នុងពោះ ឬដ៏កល់ទុកក្នុងទីដែលយើងគួរទុក ហេតុនោះនឹងក្លាយទៅជាគ្មានផលដែលធ្វើឲ្យអ្នករក្សាផុតសេចក្តីសង្ស័យទៅខាងមុខ ; ចុះបើយើងបានយកមកថ្លែងរៀបរាប់ទុកជាដំណឹងឲ្យអ្នកផងគេដឹងឮ សេចក្តីខុស-ត្រូវពិតប្រាកដគង់ហុចផលដល់អ្នកស្វែងរក ។

បន្ទាប់អំពីការបរិយាយនេះមក ខ្ញុំបាទនឹងសូមលើកយកប្រវត្តិខេត្តបាត់ដំបងមកនិទានជាលើកដំបូង ជូនលោកអ្នកស្តាប់តាមការដឹងនិងយល់ ហើយវិនិច្ឆ័យទុកតទៅ ។

មុន គ.ស. ១៩២៤ បាត់ដំបងជាអាណាខេត្តមួយយ៉ាងធំទូលាយចែកចេញជា បួន (៤) ខេត្តតូចៗមកទៀត បាត់ដំបង មង្គលបុរី, ស៊ីសុផុន, សៀមរាប មានវិសាលភាព(ទំហំដី) ៣៦.០០០ គីឡូម៉ែត្រក្រឡា

គុណ ។ ខាងក្រោយមក ខេត្តសៀមរាបបានបែកចេញជាតាណាខេត្តមួយផ្សេងដោយឡែក ខេត្តបាត់ដំបងនៅសល់វិសាលភាព ២៦.០០០ គីឡូម៉ែត្រក្រគុណទេ ។

បើតាមលោកអេម្មូនីញេរ ពណ៌នាក្នុងសៀវភៅខេត្តសៀម ត្រង់អត្ថបទថា បាត់ដំបងពីអតីតកាល មានសេចក្ដីថា មានស្ទឹងធំមួយហូរតាមភ្នំបាណន់ នឹងកាត់ភូមិអ្នកស្រុក ស្ទឹងនោះចេះតែរកតាមកំលាំងនៃទឹកហូរច្រោះ ភូមិករនៃប្រជាជនមានគេ ៗ ហូរហែតាមមាត់ស្ទឹងរហូតដល់ទីប្រជុំខេត្តសព្វថ្ងៃ ។ ក្នុងទីនោះ សៀមបានសង់បន្ទាយមួយពង់បួនជ្រុងទ្រវែងនៃគ.ស. ១៨៣៤ បន្ទាយនោះសង់ពីឥដ្ឋ មានកម្រាសយ៉ាងមាំ ស្ថិតនៅត្រើយស្ទឹងខាងជើង តែគ្មានស្នាមក្មោះទេ, ប្រវែងជ្រុងធំនៃបន្ទាយនោះ៩០០ម. នឹង ៤០០ម. ខាងជ្រុងតូច ៗ ទីក្រុងបាត់ដំបងលាតសន្ធឹងសង្ខាងនៃមាត់ស្ទឹងចំនួនជាបីយោជន៍ មានគេហស្ថានធំៗជាច្រើនដែលវិចិត្រទៅតាមការរចនាយ៉ាងវិសេស ។

ក្នុងខែមាឃ ផល្គុណប្រជាជនប្រុសស្រីក្មេងចាស់ ចូលចិត្តចេញចាកលំនៅស្ថានមកកាន់ទឹកស្ទឹងដែលមានជំរៅមិនហួសពីក្បាលជង្គង់ ក្នុងសាយណ្ហសម័យ(ពេលល្ងាច) ។ ក្នុងរដូវភ្លៀងវិញ ទឹកឡើងដល់ទៅ ៧ ឬ ៨ ម.ពេញប្រៀបដល់មាត់ច្រាំង មានទាក់តូចធំដឹកនាំទំនិញចេញចូលមនុស្សម្នាក់ៗករពាសពេញ ចេញពីផ្សារតូច-ធំមកកាន់ទីក្រុងយ៉ាងណែនណាន់ ក្នុងទីប្រជុំខេត្ត ។ នៅទីប្រជុំមានប្រជាជនប្រហែលជា ៤០.០០០ នាក់យ៉ាងតិច មានអារាមដែលសង់តាមសម័យនិយមចំនួនជា ៤០ មានព្រះសង្ឃចំនួនជា៥០០អង្គសិក្សាព្រះសទ្ធម្ម ។

ពីមុនឆ្នាំ១៩២៤ ខេត្តបាត់ដំបងមានព្រំប្រទល់ដូចតទៅនេះ ខាងជើងខាងលិចទល់នឹងប្រទេសសៀម, ខាងកើតទល់នឹងខេត្តស្ទឹងត្រែងនឹងកំពង់ធំ, អាគ្នេយ៍នឹងខាងត្បូង ទល់ទន្លេសាបនឹងខេត្តពោធិ៍សាត់ ។

ខាងក្រោយគ.ស.១៩២៤ ខេត្តបាត់ដំបងមានព្រំដូចតទៅនេះ ខាងជើងទល់នឹងប្រទេសសៀមនឹងខេត្តសៀមរាប, ខាងត្បូងទល់នឹងខេត្តពោធិ៍សាត់, ខាងកើតទល់នឹងខេត្តសៀមរាបនឹងទន្លេសាប, ខាងលិចទល់នឹងប្រទេសសៀម ។ ការបរិយាយអំពីភូមិសាស្ត្រសង្ខេបនៃខេត្តបាត់ដំបងស្មេះប៉ុណ្ណេះ សូមពណ៌នាអំពីនាមប្រចាំខេត្ត; គោះបីនិគម, ជនបទ, ឬកំរដ្ឋណាមួយ សុទ្ធតែមាននាមជាគ្រឿងសំគាល់ ដូចជាខេត្តបាត់ដំបងនេះក៏គួរតែយើងចង់ដឹងហេតុនៃនាមខេត្តនេះដែរ ចុះដូចម្ដេចបានជាមានពាក្យថាបាត់ដំបងក្នុងកិច្ចសំគាល់នៃខេត្តនេះ ?

នាមនៃខេត្តបាត់ដំបងមានរឿងដូចតទៅនេះ —

បើតាមពង្សាវតាររបស់លោក សុក-នៅ ក្រុមជំនុំ

ទំនៀមទម្លាប់ នឹងដំណឹងពីសំណាក់នៃអ្នកប្រវត្តិ-សាស្ត្រខ្លះមានន័យដូចតទៅនេះ ព្រះមហាក្សត្រដែលទ្រង់ជាអ្នកផ្ដើមហេតុ នូវទីក្រុងនេះព្រះនាមព្រះបាទសិក្ខិរុណិព្រះដំបង ខ្លះថាស្ដេចដំបងក្រញូង ទ្រង់បានសោយរាជ្យអស់រយៈពេលជា៧ឆ្នាំ៧ខែមកហើយ ។ គង់ថ្ងៃមួយទ្រង់រិតក្កក្នុងព្រះរាជហឫទ័យ ទើបត្រាស់បង្គាប់ឲ្យអ្នកហោរាសាស្ត្រមកគាល់ ទ្រង់ឲ្យហោរាទំ-នាយក្នុងរាជសម្បត្តិព្រះអង្គ អ្នកហោរាកាលបើពិទិត្យដឹងហេតុដែលខ្លួនបានគន់គូរហើយ ក៏ក្រាបទូលព្រះមហាក្សត្រតាមពិតដូចតទៅ សូមព្រះតេជះគុណដំកល់លើត្បូង សូមព្រះរាជទានទោសតាមទំនាយរបស់ទូលព្រះបង្គំ ព្រះអង្គនឹងគង់នៅបានក្នុងព្រះរាជសម្បត្តិតែ៧ឆ្នាំ៧ខែ៧ថ្ងៃទេ គិតត្រឹមពីថ្ងៃដែលទ្រង់គង់លើព្រះរាជបល្ល័ង្កមក ឥឡូវនេះទ្រង់គង់ក្នុងរាជសម្បត្តិពីពេលនោះមកដល់ពេលនេះកំណត់កាល៧ឆ្នាំនឹង៧ខែហើយ នៅសល់តែ៧ថ្ងៃតទៅមុខទៀតទេ ត្រូវអ្នកមានបុណ្យដណ្ដើមយករាជសម្បត្តិព្រះអង្គក្នុងថ្ងៃទី ៧ ដោយកំ-ណត់ សូមទ្រង់គង់ប្រថាប់ទតចុះគង់នឹងជ្រាបដោយមំសចក្ខុពិតប្រាកដ ។ ព្រះចៅដំបងក្រញូង កាលបើដឹងហេតុនេះហើយ ព្រះអង្គមានព្រះទ័យស្រពោនគ្មានរីកសោះ ដោយទ្រង់ព្រះចិន្តាថា “អញជាស្ដេចមួយរូបដែលមានឫទ្ធិដោយដំបង ចុះមាននរណាដែលមានឫទ្ធិជាងអញទៅទៀត ប្រុងមកដណ្ដើមរាជសម្បត្តិរបស់អញ ណ្ហើយចុះមុននឹងអញទទួលស្គាល់ថាគេជាអ្នកមានបុណ្យ ក៏គួរតែអញល្បងឫទ្ធិមើល បើជានឹង-ដំបងអញមិនបានអញនឹងកំទេចឲ្យម៉ត់ដូចផេះតែម្ដង” ទ្រង់ព្រះដម្រិះយ៉ាងនេះហើយ ក៏គង់នៅក្រោមនៃសេចក្ដីព្រួយបារម្ភយ៉ាងអស្ចារ្យ ។ ប្រជារាស្ត្ររបស់ព្រះអង្គ ក៏ប្រុងប្រៀបខ្លួនចាំទទួលអ្នកមានបុណ្យតាមទំនាយនៃហោរាដែរ សូមស្វះពីការច្រួលច្រ-បល់នេះសិន សូមពោលអំពីដំណើរនៃអ្នកមានបុណ្យតើបុគ្គលណា ! មាននាមជាអ្វី ? មានសេចក្ដីដំណាលថា កាលស្ដេចដំបងក្រញូងចូលលុកលុយក្នុងប្រទេស ព្រះនាងកែវក៏ត្រូវកូនព្រះអង្គជារាស្ត្រទៅសំណាក់នៅគេហស្ថានតាតហោយាយលាក់ព្រះរាជបុត្របន្ទាប់នាមស្រីកុមារមានព្រះជន្មាយុ ៤ វស្សា ព្រះមាតានឹងមេទំបាននាំព្រះរាជកុមាររត់នៅពេលនោះដើម្បីគេចឲ្យផុតពីក្រញាំនៃស្ដេចដំបងក្រញូង ; តែដោយកម្មរបស់ព្រះរាជកុមារពីអតីតមកត្រូវស្ដេចដំបងក្រញូងតាមទាន់ហើយចាប់យកព្រះរាជកុមារបោះទៅក្នុងគំនរភ្លើងដែលកំពុងឆេះ ។ ដោយបារមីដែលព្រះរាជកុមារបានសន្សំពីអតីតមកច្រើន ក៏ព្រះអង្គពុំសូវមានទទួលគ្រោះថ្នាក់អ្វីជាទម្ងន់ដែរ គឺគ្រាន់តែរលាកព្រះកាយប៉ុណ្ណោះ ទទួលសេនាទាហានរបស់ស្ដេចដំបងក្រញូងមានមេត្តាដល់ព្រះរាជកុមារ ក៏បីយកចេញចាករងើកភ្លើង យកទៅប្រគេនបព្វជិតមួយអង្គឲ្យលោកជួយរក្សា ដោយបានពណ៌នារឿងហេតុទាំងនោះប្រគេនលោកជាស្រេច ព្រះភិក្ខុអង្គនោះក៏

ព្រមទទួលទុកចិញ្ចឹមដោយការប៉ិនប្រាំងតមក ។ បំណែកពួកសេនាទាហានទាំងនោះក៏ត្រូវឡប់ទៅក្រាបទូលស្ដេចដំបង់ក្រញូងថាព្រះរាជកុមារទូលព្រះបង្គំទាំងអស់គ្នា បានប្រហារជីវិតរួចជាស្រេចហើយ ។

ដំណើរលោកកើតរបស់ព្រះរាជកុមារ ក៏បានជាសះស្បើយតាមលំដាប់មក អាស្រ័យការបីបាច់នៃកិត្តអង្គនោះ តែព្រះហស្តនឹងព្រះបាទនៃកុមារបែរជាដាប់គ្នាទៅវិញទ្រង់ពុំបានយាងទៅទីណាដោយស្រួលបាន ទាំងទៅបានដោយសារតែកកិលប៉ុណ្ណោះដូច្នេះហើយ បានជារាជកុមារមានព្រះនាមប្រាកដថាព្រំកិល ខ្លះក៏ហៅថាពញាក្រែក ។

ពេលដែលស្ដេចដំបង់ក្រញូងសោយរាជ្យគ្រប់ ៧ឆ្នាំ ៧ខែ ៧ថ្ងៃហើយអ្នកនគរទាំងឡាយក៏ផ្អើលឆោឡោគ្រប់គ្នារង់ចាំមើលដំណើរអ្នកមានបុណ្យ សូម្បីព្រំកិលហ្នឹងឯងក៏ស៊ូកកិលទៅមើលនឹងគេដែរ ព្រោះបានដំណឹងប្រាកដនេះពីសំណាក់នៃអ្នកហោរាមក ។ ទៅព្រំកិលទ្រង់ខ្សោយព្រះកាយពលពេកពេលដែលទ្រង់កកិលបែបនេះ ទើបទ្រង់ឈប់សំរាកនៅជិតមាត់ត្រពាំងមួយ ។ ពេលនោះសម្ដេចសហស្សន័យទ្រង់ជ្រាបនូវបារមីនៃទៅព្រំកិលហើយ ទ្រង់ក៏ក្លែងព្រះអង្គជាព្រាហ្មណ៍ចាស់ជរាជានេយ្យសមួយ ទាំងយាមធំមួយដែលមានគ្រឿងបញ្ចក្កុដកណ្ឋ បាយមួយសំណុំ ទឹកមួយបំពង់ ដើរមកជួបនឹងព្រំកិល ។ ឥន្ទ្រព្រាហ្មណ៍សួរថាអ្នកមានដំណើរទៅណា ? -ព្រំកិលឆ្លើយ ខ្ញុំទៅមើលអ្នកមានបុណ្យគេ ដោយខ្ញុំឮគេថាអ្នកមានបុណ្យនឹងមកថ្ងៃនេះ អើដំណើរទៅស្រុកនឹងតាដែរ តាក៏ត្រូវការចង់ឃើញអ្នកមានបុណ្យដូចជាទៅហ្នឹងដែរ ។ ឥឡូវនេះតាជួបជាឈឺពោះតាសូមផ្ញើសេះនឹងសំពាយនេះផង តាចូលព្រៃបន្តិច បើទៅឃ្លានបាយ ស្រាយបាយកញ្ចប់នេះហូបទៅ! ព្រំកិលប្រកែកថា ឱតាអើយខ្ញុំខ្វិនដើរទៅណាមកណាបានដោយលំបាកយ៉ាងនេះ ចុះឲ្យខ្ញុំរក្សាសេះតាម្ដេចកើត ខ្ញុំទទួលមិនបានទេ វេ ។ សេះតារត់បាត់ទៅ ខ្ញុំបានអ្វីសងតាវិញ ? តាឥន្ទ្រព្រាហ្មណ៍ មិនអីទេទៅសេះតានេះស្លូតណាស់ ដាក់បង្ហៀរត្រង់ណាទាំងឈរទាំងត្រង់នោះ ហើយទៅឯងក៏ព្រួយអីកាលពោលដូចនេះហើយ តាឥន្ទ្រព្រាហ្មណ៍យកបង្ហៀរសេះមកចងភ្ជាប់នឹងដៃព្រំកិល ហើយក៏កៀសខ្លួនចូលទៅក្នុងព្រៃគុម្ពោតជិតនោះទៅ ។

កាលបើតាឥន្ទ្រព្រាហ្មណ៍ទៅបាត់យូរបន្តិចសេះក៏ងើបក្បាលឡើង មានអាការដូចជាកន្ត្រាក់ដៃជើងព្រំកិលដោយហេតុត្រឹមប៉ុណ្ណោះ ព្រំកិលក៏មានអវយវជាស្អាតដូចធម្មតា នឹងអាចដើរចុះឡើងនឹងចាប់កាន់អ្វីបានដោយងាយព្រំកិលកាលបើឃើញហេតុដូចនេះហើយ ក៏កើតសេចក្ដីត្រេកអរក្នុងចិត្តឥតឧបមា រួចចាប់យកទឹកបំពង់មកលាបខ្លួនពាសពេញអំណាចនៃទឹកនោះ ស្នាមដំណើរលោកកើតក៏វិនាសបាត់ភ្លាម តមកព្រះរាជកុមារបានស្រាយបាយកញ្ចប់មក

(នៅមានត)

# ថ្វាយព្រះពរជ័យ

យើងខ្ញុំសមា- គមមិត្តសាលា បាលី គ្រប់ប្រាណ សូមថ្វាយព្រះពរ ដល់មហាក្សត្រិយ៍ក្សាន្ត ជន្មាយុបាន សាមបួនព្រះវស្ស ។

យើងខ្ញុំបង្គំ ទសករប្រណម្យ ដាក់លើសិរសា ទូនអង្គអភិវាទ គុណាថសាស្ដា ជាគ្រូអស់មហា- ជនទាំងគតត្រៃ ។ សូមថ្វាយបង្គំ ព្រះធម៌ឧត្ដម ជាទូកទថ្លៃ ចំឡងអស់សត្វ ឆ្លងកាត់ជលស័យ ដាក់ដល់ត្រើយព្រះ- ដ៏និព្វាននាយ ។ សូមបង្គំផង ចំពោះព្រះសង្ឃ សាវកកើតឆាយ ទ្រទ្រង់គាំទ ឧហាតខ្វល់ខ្វាយ ទូន្មានចិត្តកាយ នៃពុទ្ធជន សូមគុណត្រៃរតន៍ ជួយអង្គម- ហាក្សត្រិយ៍ ប្រសើរពេកពន់ ឥតមានទរ ណា ថ្ងៃថ្វារិះគន់ លើព្រះគុណធ្ងន់ ក្នុងផែនពសុធា ។ សូមព្រះអង្គមាន ព្រះជ័យ អាចហាន បំពានបំពា ទូរទបស័គ្គ អនគ្ឃ នាមា លើពេញអស្ចារ្យ គ្មានអ្នកណាដល់ៗ សូមជួយជ្រោមជ្រែង រីងរិតក្រៃលែង តែងសម្រេចផល គឺព្រះនិព្វាន ជាស្ថាននិរមល បានសុខសាន្តដល់ តុសិតសួគ៌ា ។ មួយទៀត សូមទ្រង់ មានជោគជ័យអង្គ ចំរើនវឌ្ឍនា បានរក្សាកេរ្តិ៍ តំណែលសាសនា ដែលព្រះសាស្ដា ទ្រង់ទូន្មានមក ។ សូមមានព្រះជ័យ សុខសាន្តប្រិមប្រិយ៍ តាមដោយអនុ- យោគ កុំមានព្រួយកាយ សប្បាយផ្លូវលោក ផ្លូវធម៌គ្មានសោក វិមោក្ខអនន្ត ។ យើងខ្ញុំ ទាំងឡាយ សូមវន្ទាថ្វាយ ព្រះពរមហន្ត សូមកបសត្រូវគ្រប់ ពុំមានរកអន់ សូមព្រះ អង្គធន់ ក្នុងភពសម្បត្តិ ៗ ប្រកបជោគជ័យ កាយមនោប្រពៃ ប៉ុនប៉ងឡើងរដ្ឋ កម្ពុជាឯក អនេកមហាក្សត្រិយ៍ ទូនអង្គប្រតិបត្តិ ថ្វាយ ពរជោគជ័យ ។

សូមប្រជារាស្ដ្រ ដែលនៅពេញពាស ជ្រោកកោនអាស្រ័យ ក្រោមម្លប់បេស្វា នៃបារមីថ្លៃ បានសុខប្រពៃ គ្រប់ទិសទី ។

ឱ យោ! ព្រះករុណា

ឱ យោ! កម្ពុជាសុខសាន្ត

មហាអ៊ីវ - ឌុម

ជំរាបមិត្តអ្នកអាន ទស្សនាវដ្ដីដែលបានចេញជូនមិត្តអានក្នុងរយៈកាលឆ្នាំ ១៩៥៤ ជិតផុតហើយ ដល់ឆ្នាំ ១៩៥៥ ខាងមុខនេះក្រែងលោមានមិត្តពុញព្រាក់មិនស្ម័គ្រចិត្តជាវតទៅទៀតក៏សូមដំណឹង បើមិត្តនៅតែស្ម័គ្រអានក៏សូមស្វាគមន៍ ខ្ញុំនឹងខំរាយបាត់ការក្នុងឆ្នាំថ្មីតទៅ

ហួត-ហៀម